N°: 29-30
15-8-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ២៩.៣០ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសម្រេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

LAW

CH. Kimpo

មាតិកា

I -ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៤.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៥ តែងតាំងលោក អ៊ុំ ប៊ុណ្ណា ជាឧកញ៉ា	១៧៥០
០៤.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៦ តែងតាំងនិងតម្លើងឋានន្តរស័ក្តិ ជូនឯកឧត្តម ងួន សឿ	១៧៥១
០៧.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧ /១៤៧ កែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា តែងតាំងឯកឧត្តម អ៊ឹង ហួត ជានាយករដ្ឋមន្ត្រី ទី១ —	១៧៥២
១១.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៨ តែងតាំងនិងតំលើងឋានន្តរស័ក្តិ ជូនឯកឧត្តម កែ គឹមយ៉ាន	១៧៥៣
១១.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៩ តែងតាំង និងតំលើងឋានន្តរសក្តិ ជូនឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល សារឿន	១៧៥៤
១១.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៥០ តែងតាំង និងតំលើងឋានន្តរសក្តិ ជូនឯកឧត្តម ឧត្តមសេនីយ៍ឯក មាស សុភា	១៧៥៥
១១.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៥១ តែងតាំង និងតំលើងឋានន្តរសក្តិ ជូនឯកឧត្តម ឧត្តមសេនីយ៍ឯក ហុក ឡុងឌី	១៧៥៦
១១.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៥២ តែងតាំង និងតំលើងឋានន្តរសក្តិ ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ តេង សាវង្ស	១៧៥៧
១១.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៥៣ តែងតាំង និងតំលើងឋានន្តរសក្តិ ជូនឯកឧត្តម ឧត្តមសេនីយ៍ត្រី ចក់ ឡេង	១៧៥៨
១១.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៥៤ តែងតាំង នឹងឯកឧត្តម ណា ម៉ារឌី	១៧៥៩
១១.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៥៥ តែងតាំង និងតំលើងឋានជូន ឯកឧត្តម ពេជ គឹមអេង ជាទីប្រឹក្សាក្រសួងមហាផ្ទៃ	១៧៦០

០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៤៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៣២
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៤៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៣៣
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៤៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៣៤
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៥០ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល នៃអគ្គិសនីកម្ពុជា	១៨៣៥
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៥១ អនក្រ.តត ស្តីពីការបំពាក់ឋានន្តរស័ក្តិជូន នាយនគរបាលជាតិ	១៨៣៧
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៥២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៣៨
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៥៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៣៩
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៥៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៤០
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៥៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៤១
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៥៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៤២
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៥៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៤៣
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៥៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៤៤
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៥៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៤៥
០៦.៨.១៩៩៧	អនុក្រឹត្យលេខ ១៦០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៤៦
១៥.៨.១៩៩៧	អនុក្រឹត្យលេខ ១៦១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៤៧

២- សេចក្តីសំរេច

០៥.៨.១៩៩៧	សេចក្តីសំរេចលេខ ២៧ សសរ ស្តីពីការផ្ទេរសិទ្ធិ	១៨៤៨
១១.៨.១៩៩៧	សេចក្តីសំរេចលេខ ២៨ សសរ ស្តីពីការផ្ទេរសិទ្ធិ	១៨៤៩

III - ការងារបណ្តាក្រសួង

១- ទីស្តីការគណៈរដ្ឋមន្ត្រី

ប្រកាស

០១.៨.១៩៩៧	ប្រកាសលេខ ៦៥ ប្រក.បល ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៥០
០១.៨.១៩៩៧	ប្រកាសលេខ ៦៦ ប្រក.បល ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៥១

០១.៨.១៩៩៧ ប្រកាសលេខ ៦៧ ប្រក.បល ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៥២
០១.៨.១៩៩៧ ប្រកាសលេខ ៦៨ ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៥៣
០១.៨.១៩៩៧ ប្រកាសលេខ ៦៩ ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៥៤
០១.៨.១៩៩៧ ប្រកាសលេខ ៧០ ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៥៥

២- ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

០៨.៨.១៩៩៧ ប្រកាសលេខ ២២៣ ពណ.បល.ប្រក ស្តីពីការបង្កើតការិយាល័យអាស៊ាន ១៨៥៦
០៨.៨.១៩៩៧ ប្រកាសលេខ ២២៤ ពណ.គន.ប្រក ស្តីពីការប្រគល់ទីតាំងស្ថានីយ៍ប្រេង "អេសសូ" ១៨៥៧

៣- ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រកាស

១៣.៨.១៩៩៧ ប្រកាសលេខ ៣៣៤ ប្រក ស្តីពីការប្រគល់សិទ្ធិចុះហត្ថលេខា ១៨៥៨

៤- ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

០៤.៨.១៩៩៧ ប្រកាសលេខ ២១១/៩៧ ពម.ប្រក អនុញ្ញាតជូនលោក SHINICHI HARADA KAZUMASA OKAJIMA តំណាង ណះគ តម្លើងផ្ទាយរណប ១៨៥៩
០៥.៨.១៩៩៧ ប្រកាសលេខ ២១២/៩៧ ពម្ម.ប្រក អនុញ្ញាតឱ្យលោក ទៀ ថេន បើកអាជីវកម្មរោងពុម្ពឈ្មោះ "ខេមរារ្យ" ១៨៦១

៥- ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

សេចក្តីសំរេច

១៣.៨.១៩៩៧ សេចក្តីសំរេចលេខ ៣៣៩ សសរ.កសក ស្តីពីការប្រគល់ភារកិច្ចបន្ថែមបណ្តោះអាសន្នជូនឯកឧត្តម អនុរដ្ឋលេខាធិការ ឆាន់ សាផាន និង ឯកឧត្តម ឈុន សារ៉េត ១៨៦២

ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- ត្រូវបានតម្លើងឋានន្តរស័ក្តិ និងឋានៈជូនឯកឧត្តម **ខួន សៀរ** ជាបេសកជន ពិសេសសម្តេចនាយករដ្ឋមន្ត្រីទី២ មានឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** នគរបាលជាតិ នៃក្រសួង មហាផ្ទៃ មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសេចក្តីអនុម័តទុកចិត្តរបស់រដ្ឋសភា ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ លើសំណើរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ .- កែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

ឯកឧត្តម **អ៊ឹង ហួត** ជានាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ជំនួសសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ**។

មាត្រា ២ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧
ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ នស/រកត/០៨៩៧/១៤៨

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជ
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដាឆ្ន ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវបានតែងតាំងនិងតម្លើងឋានៈជូនឯកឧត្តម ឧត្តមសេនីយ៍ឯក ចែក **គឹមយ៉ាន** ជាទីប្រឹក្ សហអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែ លើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុ ព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជព្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវបានតែងតាំងនិងតម្លើងឋានៈជូនឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ុល សារឿន**ជាទីប្រឹក្សាសេនាធិការអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ .- នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជព្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ នស/រកត/០៨៩៧/១៥០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវបានតែងតាំងនិងតម្លើងឋានៈជូនឯកឧត្តម ឧត្តមសេនីយ៍ឯក **មាស សុភា** ជាទីប្រឹក្សា សហអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខ ងារបច្ចុប្បន្ន ។

មាត្រា ២ .- នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ៩ស/រកត/០៨៩៧/១៥៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- ត្រូវបានតែងតាំងនិងតម្លើងឋានៈជូនឯកឧត្តមឧត្តមសេនីយ៍ឯក **ហុក ឡុងឌី** ជាទីប្រឹក្សាសហអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ .- នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៥២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១. ត្រូវបានតែងតាំងនិងតម្លើងឋានៈជូនឯកឧត្តម ឧត្តមសេនីយ៍ទោ **តេង សាវង្ស** ជាទីប្រឹក្សា សហអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២. នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣. ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ នស/រកត/០៨៩៧/១៥៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវបានតែងតាំងនិងតម្លើងឋានៈជូនឯកឧត្តម ឧត្តមសេនីយ៍ត្រី **ចក់ ឡេង** ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ .- នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៥៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .. ត្រូវបានតែងតាំងនិងតម្លើងឋានៈជូនឯកឧត្តម **ឈា ម៉ារឌី** ជាទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រីទី២ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែម លើមុខ ងារបច្ចុប្បន្ន ។

មាត្រា ២ .. នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣ .. ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជព្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ នស/រកត/០៨៩៧/១៥៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

ព្រះរាជបញ្ញត្តិ

ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឯកឧត្តម **ពេជ គឹមអេង** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ .- នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជព្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

II- រាជរដ្ឋាភិបាល

១ - អនុក្រឹត្យ

អនុក្រឹត្យលេខ ៣៥ អនក្រ.បក

ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃ ទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២ ន.ស . ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ស្តីពីការរៀ និង ការប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/ រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/១០៩៦/១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពី បង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសាឆ្នាំ ១៩៩៦ ស្តីពីការរៀ និងការ ប្រព្រឹត្តទៅ របស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រីថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧

សំរេច

ជំពូក ១

បទបញ្ញត្តិទូទៅ

មាត្រា ១ .- អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាពនៃក្រសួងទេសចរណ៍ និងកំណត់បេសកកម្មរបស់ក្រ និងមុខការនៃអគ្គនាយកដ្ឋាន និងនាយកដ្ឋាននានា ។

ជំពូក ២

បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា ២ .- ក្រសួងទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ .- ក្រសួងទេសចរណ៍ មានមុខងារនិងភារកិច្ចដូចតទៅ ៖

- កំណត់នយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ និងរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍
- ជំរុញលើកទឹកចិត្តការងារវិនិយោគទុន ក្នុងវិស័យទេសចរណ៍ ដោយយោងលើការអភិវឌ្ឍន៍ជា យុទ្ធសាស្ត្ររបស់ជាតិ
- រៀបចំគ្រប់គ្រងវិស័យឧស្សាហកម្មទេសចរណ៍
- តំរង់ទិសនិងត្រួតពិនិត្យរាល់សេវា ដែលបំរើឱ្យវិស័យទេសចរណ៍
- កំណត់រៀបចំតំរង់ទិស ត្រួតពិនិត្យ និងថែរក្សារមណីយដ្ឋានធម្មជាតិ រមណីយដ្ឋានកែច្នៃទេសចរណ៍នានា មជ្ឈមណ្ឌលទេសចរណ៍ តំបន់អភិវឌ្ឍន៍ទេសចរណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា
- សិក្សាសំណើសុំបង្កើត ទទួលស្គាល់និងត្រួតពិនិត្យសាលាឯកជន និងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ បំរើឱ្យវិស័យទេសចរណ៍
- ធ្វើការផ្សព្វផ្សាយវិស័យទេសចរណ៍ ក្នុងនិងក្រៅប្រទេស
- ចាត់តំណាងនៅក្រៅប្រទេសដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ចុះហត្ថលេខាលើកិច្ចសន្យាអនុវត្តនានា ដែលទាក់ទងទៅលើវិស័យទេសចរណ៍ក្រោយពីបានគោលការពីរាជរដ្ឋាភិបាល
- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មដល់ក្រុមហ៊ុនទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ និងមគ្គ [illegible]

ពិនិត្យលើសេវាទេសចរណ៍និងអាជីវកម្មផ្សេងៗទៀតដែលទាក់ទងនឹងវិស័យទេសចរណ៍

អធិការកិច្ចវិស័យទេសចរណ៍ ។

ក្រសួងទេសចរណ៍មានរចនាសម្ព័ន្ធ ដូចតទៅ ៖

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អធិការដ្ឋាន

- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានទេសចរណ៍
- អង្គភាពមូលដ្ឋាន ។

អង្គការលេខរបស់ក្រសួងទេសចរណ៍ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

ជំពូក ៣

ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ៥ .- ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិនៃអនុក្រឹត្យ លេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

ជំពូក ៤

អធិការដ្ឋាន

មាត្រា ៦ .- អធិការដ្ឋានរបស់ក្រសួងទេសចរណ៍ ទទួលបន្ទុក :

- ធ្វើអធិការកិច្ចជាប្រចាំ ទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តិទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ច នោះ និងពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅ របស់អង្គភាពទាំងនោះ
- ប្រតិបត្តិភារកិច្ចតាមការដែលរដ្ឋមន្ត្រីបានប្រគល់ទុកចិត្ត ។ អធិការដ្ឋានដឹកនាំដោយអធិការ មួយនាក់អាច អមដោយអធិការរងមួយរូប ឬច្រើនរូបជួយធ្វើការទៅតាមការចាំបាច់ ។

ជំពូក ៥

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

មាត្រា ៧ .- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទទួលបន្ទុក :

ក- ក្នុងវិស័យរដ្ឋបាល

- សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និង អង្គភាពមូលដ្ឋានក្រោមឱវាទ
- គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង
- សរុបនិងធ្វើរបាយការណ៍ការងារនិងសកម្មភាពផ្សេងៗរបស់ក្រសួង ។

ខ- ក្នុងវិស័យគ្រប់គ្រងបុគ្គលិក

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនង និង រដ្ឋ លេខាធិការដ្ឋានមុខងារសាធារណៈ
- រៀបចំរាល់លិខិតរដ្ឋបាល សំរាប់ការគ្រប់គ្រងអាជីព
- ធ្វើកម្មវិធីពិព័ណ៌ពេងឯកទេស និងធនធានមនុស្សរបស់ក្រសួង
- វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូងនិងបន្ត ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ និងអនុវត្តនីនយោបាយនោះ
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពត៌មានប្រតិបត្តិ ។

គ- ក្នុងវិស័យគ្រប់គ្រងសំភារៈ និងបរិក្ខារ

- ប្រមូលផ្តុំតម្រូវការធ្វើកម្មវិធីចំណាយគ្រប់គ្រង ការរៀបចំជួសជុលសំភារៈ និងបរិក្ខាររបស់ ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈនិងធ្វើបញ្ជីសារពើភ័ណ្ឌ
- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួងព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់
- ទទួលនិងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពខេត្ត ក្រុងនានា
- កាន់បញ្ជីជាប្រចាំនូវសាលាកប័ត្រ និងគណនេយ្យរូបធាតុ
- ពត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិ លទ្ធកម្មសាធារណៈ ។

ឃ -ក្នុងវិស័យគ្រប់គ្រងបន្ទុកគណនីនិងហិរញ្ញវត្ថុ

- លើកគំរោងថវិកាក្រសួង និងតាមដានលើកពីការប្រតិបត្តិ
- គ្រប់គ្រងចំណូល ចំណាយឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ
- ប្រមូលផ្តុំនិងសំរបសំរួលជំពូកថវិកា
- តាមដានលើកការគ្រប់គ្រងគណនីពិសេស
- ប្រមូលផ្តុំនិងសំរបសំរួលរាល់ការចំណាយរបស់ក្រសួង
- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តន៍លទ្ធកម្មសាធារណៈ ។

ជំពូក ៦

អគ្គនាយកដ្ឋានទេសចរណ៍

មាត្រា ៨ .- អគ្គនាយកដ្ឋានទេសចរណ៍ ទទួលបន្ទុកធ្វើការទំនាក់ទំនងសំរបសំរួលគ្រប់គ្រងការងារសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ ផែនការអភិវឌ្ឍន៍ អប់រំបណ្តុះបណ្តាល អភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ និងឧស្សាហកម្មទេសចរណ៍ ។ អគ្គនាយកដ្ឋានទេសចរណ៍ ដឹកនាំដោយអគ្គនាយកមួយរូបដែលអាចអមដោយ អគ្គនាយករងជាជំនួយការ តាមការចាំបាច់ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន ០៥ ដូចតទៅ :

- នាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍
- នាយកដ្ឋានផែនការអភិវឌ្ឍន៍
- នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌
- នាយកដ្ឋានអប់រំបណ្តុះបណ្តាល
- នាយកដ្ឋានឧស្សាហកម្មទេសចរណ៍ ។

មាត្រា ៩ .- នាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ទទួលបន្ទុក :

ក. ការងារសិក្សាទីផ្សារ

- ប្រមូលផ្តុំពតិមាន និងធ្វើស្ថិតិដើម្បីធ្វើការវិភាគ
- ចងក្រងឯកសារដែលទាក់ទងទៅនឹងវិស័យទេសចរណ៍
- លើកកំពស់កិតផ្សព្វផ្សាយពតិមានដល់អ្នកទេសចរណ៍
- គិតគូរកែលំអការស្វាគមន៍ដល់ភ្ញៀវទេសចរណ៍
- សហការជាមួយក្រុមហ៊ុនដឹកជញ្ជូននានា ដើម្បីប្រមូលពតិមានជារៀងរាល់ថ្ងៃពីការធ្វើដំណើរ ហើយកត់ត្រានិងជូនដំណឹងដល់ភ្ញៀវទេសចរណ៍ជាបន្ទាន់ក្នុងករណី ដែលមានការផ្លាស់ប្តូរក្នុងការ ធ្វើដំណើរ ។

ខ. ការងារផ្សព្វផ្សាយ

- រក្សាឱ្យបានជាអចិន្ត្រៃយ៍នូវការប្រាស្រ័យ និងនូវទំនាក់ទំនងរវាងនាយកដ្ឋាន ជាមួយភ្នាក់ងារតំណាងនៅក្រៅប្រទេសដែលទទួលបន្ទុកការងារផ្សព្វផ្សាយពត៌មានដោយគោរពរក្សានូវវប្បធម៌ប្រពៃណីជាតិ
- ទំនាក់ទំនងជាមួយនិងសារពតិមានជាតិ និងអន្តរជាតិដែលមានប្រចាំនៅប្រទេសកម្ពុជាហើយ និងបណ្តាញឃោសនាបរទេសសំខាន់ៗ

- រៀបចំនិងចូលរួមក្នុងពិព័រណ៍អន្តរជាតិនានា
- គ្រប់គ្រងភ្នាក់ងារតំណាងនៅបរទេស
- ផ្សព្វផ្សាយពត៌មានដល់អ្នកទេសចរណ៍
- ផលិតឯកសារផ្សព្វផ្សាយនានា ។

មាត្រា១០ .- នាយកដ្ឋានផែនការអភិវឌ្ឍន៍ទទួលបន្ទុក :

- គ្រប់គ្រងពត៌មាន និងស្ថិតិទាក់ទងលើវិស័យទេសចរណ៍
- សិក្សាការអនុវត្តន៍ កំណត់ការរៀបចំទិន្នន័យនិងលើកគំរោងអភិវឌ្ឍន៍លើវិស័យទេសចរណ៍
- សិក្សាស្រាវជ្រាវលើកិច្ចសហប្រតិបត្តិការអន្តរជាតិ
- គ្រប់គ្រងកម្មវិធីជំនួយអន្តរជាតិ ។

មាត្រា១១ .- នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ទទួលបន្ទុក :

- សហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាមួយអាជ្ញាធរនានាក្នុងការអភិវឌ្ឍន៍លើ វិស័យទេសចរណ៍វប្បធម៌
- សហការជាមួយនាយកដ្ឋានផែនការអភិវឌ្ឍន៍ដើម្បីសិក្សាស្រាវជ្រាវតំបន់ទេសចរណ៍នៅ ព្រះរាជាណាចក្រកម្ពុជា
- ថែរក្សាអត្តសញ្ញាណជាតិនិងតម្លៃវប្បធម៌ជាតិក្នុងកិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ ។

មាត្រា១២ .- នាយកដ្ឋានអប់រំបណ្តុះបណ្តាលទទួលបន្ទុក :

- តំរង់ទិសក្នុងការបណ្តុះបណ្តាលហ្វឹកហ្វឺន មុខវិជ្ជាជីវៈទេសចរណ៍និងសេវាកម្មផ្សេងៗទៀត ដែលបំរើឱ្យវិស័យទេសចរណ៍តាមកាលៈទេសៈតំរូវការ និងធ្វើឱ្យសំរេចការងារនេះ
- ត្រួតពិនិត្យសាលាឯកជនដែលបណ្តុះបណ្តាលជាទូទៅនូវវិស័យទេសចរណ៍ ដោយសំរបសំរួលជាមួយក្រសួងអប់រំយុវជននិងកីឡា ។

មាត្រា១៣ .- នាយកដ្ឋានឧស្សាហកម្មទេសចរណ៍ទទួលបន្ទុក :

- ពិនិត្យសំណើសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្ម ក្រុមហ៊ុនទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ និងមគ្គុទ្ទេសក៍ទេសចរណ៍
- សហការជាមួយនាយកដ្ឋានពាក់ពន្ធ័មន្ទីរទេសចរណ៍ខេត្ត-ក្រុងនិងអាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់តាំងត្រួតពិនិត្យមូលដ្ឋានអាជីវកម្មសេវាកម្មផងទៃទៀត ដែលទាក់ទងនិងវិស័យទេសចរណ៍ ។

ជំពូក ៧

អង្គភាពមូលដ្ឋាន

មាត្រា១៤ .- នៅតាមខេត្ត-ក្រុងនីមួយៗ មានមន្ទីរទេសចរណ៍ខេត្ត-ក្រុងនិងរចនាសម្ព័ន្ធខ្សែបណ្តោយតាមថ្នាក់ខ័ណ្ឌ ស្រុកដែលទទួលបន្ទុកអនុវត្តនិងសំរបសំរួលសកម្មភាពរបស់ក្រសួង ។

ជំពូក ៨

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា១៥ .- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

ជំពូក ៩

អវសានបញ្ញត្តិ

មាត្រា១៦ .- ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

មាត្រា១៧ .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១៨ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី និងរដ្ឋលេខា ធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀង១ខ្លួនអនុវត្តអនុក្រឹត្យនេះដែលចូល ជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រីទី២

រដ្ឋលេខាធិការក្រសួងទេសចរ

ហត្ថលេខា : **ថោង ខុន**

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៣៤ អនក្រ បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧

អង្គការលេខ របស់ក្រសួងទេសចរណ៍



* * *

អនុក្រឹត្យ លេខ ៣៥ អនក្រ.បក

ស្តីពីការបង្កើតស្រុកសំឡូតចំណុះខេត្តបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

ឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ ...ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តី

ការបង្កើតក្រសួងមហាផ្ទៃ

- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ .- ត្រូវបានបង្កើតស្រុកសំឡូត ។

មាត្រា ២ .- ស្រុកសំឡូត ត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបាត់ដំបង ។

មាត្រា ៣ .- ស្រុកសំឡូត ត្រូវបានបង្កើតឃុំចំនួន ០៦ ចំណុះ គឺឃុំតាតោក ឃុំកំពង់ល្ពៅ ឃុំអូរសាម

ឃុំស៊ុង ឃុំសំឡូត និងឃុំមានជ័យ ។

មាត្រា ៤ .- ស្រុកសំឡូតត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់នឹងព្រំប្រទល់ក្រុងប៉ៃលិន និងស្រុករតនមណ្ឌលខេត្តបាត់ដំបង
- ខាងត្បូងទល់នឹងព្រំប្រទល់ស្រុកវាលវែង នៃខេត្តពោធិសាត់ ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុកបាណន់ នៃខេត្តបាត់ដំបង ។
- ខាងលិចទល់នឹងព្រំប្រទល់ ព្រះរាជាណាចក្រថៃឡង់ដ៍ ។

មាត្រា ៥ .- ទីតាំងសាលាស្រុកសំឡូត ស្ថិតនៅក្នុងឃុំស៊ុង ។

មាត្រា ៦ .- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខា

ធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋានត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខា

តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ៣៦ អនក្រ.បក

ស្តីពីការបង្កើតស្រុកសំពៅលូន ចំណុះខេត្តបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្ដីពី ការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ .. ត្រូវបានបង្កើតស្រុកសំពៅលូន ដោយកាត់យកភូមិសាស្ត្រមួយចំណែកពី ខេត្តបន្ទាយមានជ័យ ។

មាត្រា ២ .. ស្រុកសំពៅលូន ត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបាត់ដំបង ។

មាត្រា ៣ .. ស្រុកសំពៅលូនត្រូវបានបង្កើតឃុំចំនួន ០៦ ចំណុះ គឺ ឃុំសំពៅលូន ឃុំអង្គរបាន ឃុំតាស្ដា ឃុំសន្តិភាព ឃុំសិរីមានជ័យ ឃុំជ្រៃសីមា ។

មាត្រា ៤ .. ស្រុកសំពៅលូនត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់នឹងព្រំប្រទល់ស្រុកម៉ាឡៃ នៃខេត្តបន្ទាយមានជ័យ ។
- ខាងត្បូងទល់នឹងព្រំប្រទល់ក្រុងភ្នំព្រឹក នៃខេត្តបាត់ដំបង ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុកបវេល នៃខេត្តបាត់ដំបង ។
- ខាងលិចទល់នឹងព្រំប្រទល់ ព្រះរាជាណាចក្រថៃឡង់ដ៏ ។

មាត្រា ៥ .. ទីតាំងសាលាស្រុកសំពៅលូន ស្ថិតនៅក្នុងឃុំតាស្ដា ។

មាត្រា ៦ .. បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវជានិរាករណ៍ ។

មាត្រា ៧ .. សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ៣៧ អនក្រ.បក
ស្តីពីការបង្កើតស្រុកភ្នំព្រឹក ចំណុះខេត្តបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី... និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុ...
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀ... និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ... ការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ ..- ត្រូវបានបង្កើតស្រុកភ្នំព្រឹក ។

មាត្រា ២ ..- ស្រុកភ្នំព្រឹក ត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបាត់ដំបង ។

មាត្រា ៣ ..- ស្រុកភ្នំព្រឹក ត្រូវបានបង្កើតឃុំចំនួន ០៥ ចំណុះ គឺ ឃុំភ្នំព្រឹក ឃុំពេជ្រចិន្តា ឃុំចក្រី ឃុំ... រាំងធ្លាក់ និងឃុំអូររំដួល ។

មាត្រា ៤ ..- ស្រុកភ្នំព្រឹកត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់នឹងព្រំប្រទល់ស្រុកសំពៅលូន នៃខេត្តបាត់ដំបង ។
- ខាងត្បូងទល់នឹងព្រំប្រទល់ស្រុកកំរៀង នៃខេត្តបាត់ដំបង ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុកបវេល នៃខេត្តបាត់ដំបង ។
- ខាងលិចទល់នឹងព្រំប្រទល់ ព្រះរាជាណាចក្រថៃឡង់ដ៍ ។

មាត្រា ៥ ..- ទីតាំងសាលាស្រុកភ្នំព្រឹក ស្ថិតនៅក្នុងឃុំភ្នំព្រឹក ។

មាត្រា ៦ ..- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋានត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ៣៨ អនក្រ.បក

ស្តីពីការបង្កើតស្រុកកំរៀង ចំណុះខេត្តបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ .- ត្រូវបានបង្កើតស្រុកកំរៀង។

មាត្រា ២ .- ស្រុកកំរៀង ត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបាត់ដំបង ។

មាត្រា ៣ .- ស្រុកភ្នំកំរៀងត្រូវបានបង្កើតឃុំចំនួន ០៥ ចំណុះ គឺ ឃុំកំរៀង ឃុំបឹងរាំង ឃុំអូរដា ឃុំត្រាង និងឃុំតាសែន ។

មាត្រា ៤ .- ស្រុកកំរៀង ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់នឹងព្រំប្រទល់ស្រុកភ្នំព្រឹក នៃខេត្តបាត់ដំបង។

- ខាងត្បូងទល់នឹងព្រំប្រទល់ក្រុងប៉ៃលិន ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុកបវេល នៃខេត្តបាត់ដំបង ។
- ខាងលិចទល់នឹងព្រំប្រទល់ ព្រះរាជាណាចក្រថៃឡង់ដ៍ ។

មាត្រា ៥ .- ទីតាំងសាលាស្រុកកំរៀង ស្ថិតនៅក្នុងឃុំអូរដា។

មាត្រា ៦ .- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋានត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ៣៩ អនក្រ.បក

ស្តីពីការបង្កើតស្រុកម៉ាឡៃ ចំណុះខេត្តបន្ទាយមានជ័យ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ .- ត្រូវបានបង្កើតស្រុកម៉ាឡៃ។

មាត្រា ២ .. ស្រុកម៉ាឡៃ ត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបន្ទាយមានជ័យ ។

មាត្រា ៣ .. ស្រុកម៉ាឡៃ ត្រូវបានបង្កើតឃុំចំនួន ០៤ ចំណុះ គឺ ឃុំទួលពង្រ ឃុំអូរសំព័រ ឃុំអូរស្រឡៅ ឃុំម៉ាឡៃ និងឃុំបឹងបេង ។

មាត្រា ៤ .. ស្រុកម៉ាឡៃ ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់និងព្រំប្រទល់ស្រុកអូរជ្រៅ នៃខេត្តបន្ទាយមានជ័យ និងព្រំប្រទល់ព្រះរាជាណាចក្រថៃឡង់ដ៍ ។
- ខាងត្បូងទល់នឹងព្រំប្រទល់ស្រុកសំពៅលូន នៃខេត្តបាត់ដំបង ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុកមង្គលបូរី នៃខេត្តបន្ទាយមានជ័យ ។
- ខាងលិចទល់នឹងព្រំប្រទល់ ព្រះរាជាណាចក្រថៃឡង់ដ៍ ។

មាត្រា ៥ .. ទីតាំងសាលាស្រុកម៉ាឡៃ ស្ថិតនៅក្នុងឃុំម៉ាឡៃ ។

មាត្រា ៦ .. បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ .. សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋានត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ៤០ អនក្រ.បក

ស្តីពីការបង្កើតស្រុកវាលវែង ចំណុះខេត្តពោធិ៍សាត់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ .. ត្រូវបានបង្កើតស្រុកវាលវែង។

មាត្រា ២ .. ស្រុកវាលវែង ត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តពោធិ៍សាត់ ។

មាត្រា ៣ .. ស្រុកវាលវែង ត្រូវបានបង្កើតឃុំចំនួន ០៥ ចំណុះ គឺ ឃុំអូរសោម ឃុំក្រពើពីរ ឃុំអន្លង់រាប ឃុំប្រម៉ោយ និងឃុំថ្មដា ។

មាត្រា ៤ .. ស្រុកវាលវែង ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់នឹងព្រំប្រទល់ស្រុកមោងឬស្សី នៃខេត្តបាត់ដំបង និងស្រុកបាកាន ខេត្តពោធិ៍សាត់ ។
- ខាងត្បូងទល់នឹងព្រំប្រទល់ស្រុកថ្មបាំង នៃខេត្តកោះកុង ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុកភ្នំក្រវាញ នៃ ខេត្តពោធិ៍សាត់ ។
- ខាងលិចទល់នឹងព្រំប្រទល់ ស្រុកសំឡូត នៃខេត្តបាត់ដំបង និងព្រំប្រទល់ព្រះរាជាណាចក្រថៃឡង់ដ៍ ។

មាត្រា ៥ .. ទីតាំងសាលាស្រុកវាលវែង ស្ថិតនៅក្នុងឃុំប្រម៉ោយ ។

មាត្រា ៦ .. បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ .. សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋានត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ៤១ អនក្រ.បក

ស្តីពីការអនុវត្តន៍ព្រះរាជក្រម លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញ. ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០១ នស/ ចុះថ្ងៃទី២៨ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស./រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស./រកម/១២០៥/០៧ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៥ ស្តីពីច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៦
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស./រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៧
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

ជំពូក ១

បទបញ្ញត្តិទូទៅ

មាត្រា ១ .-

១.១ ដោយអនុលោមតាមនយោបាយរៀបចំរចនាសម្ព័ន្ធ ផ្នែកសហគ្រាសសាធារណៈ ជាថ្មីឡើងវិញ របស់ រាជរដ្ឋាភិបាល ចាប់ពីថ្ងៃចូល ជាធរមាននៃ អនុក្រឹត្យនេះតទៅ ក្នុងរយៈពេលមួយ

ឆ្នាំ គ្រប់អង្គភាពឧស្សាហកម្ម និងពាណិជ្ជកម្មរបស់រដ្ឋដែលពុំទាន់មាននីតិបុគ្គលភាពគតិយុ អង្គភាពសាធារណៈ និងសហគ្រាសដែលជាភាគកម្មជាកម្មសិទ្ធិរបស់រដ្ឋ ត្រូវក្លាយជាកម្មវត្ថុ វិធានណា មួយក្នុង ចំណោមវិធានដូចខាងក្រោមនេះ :

១-ធ្វើការជំរះបញ្ជី

២-ចាត់ថ្នាក់ចូលក្នុងប្រភេទគតិយុត្តណាមួយនៃបណ្តាប្រភេទគតិយុត្ត ដែលមានចែងក្នុងច្បាប់ គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច (គ.ស.ស) ក្រុមហ៊ុនរដ្ឋ (ក្រ. ក្រុមហ៊ុន ចំរុះ(ក្រ,ច) ដែលភាគកម្មសាធារណៈមានចំនួនភាគច្រើន ឬភាគតិចនៃដើ ទុនសរុប ។ ក្រោយរយៈពេលមួយឆ្នាំ បណ្តាអង្គភាពឧស្សាហកម្ម និងពាណិជ្ជកម្មរបស់ ដែលពុំទាន់ មាននីតិបុគ្គល [illegible] និងប្រព័ន្ធបញ្ជី [illegible] ចាត់ថ្នាក់ខាងលើទេ នោះត្រូវ ចាត់ស្វ័យប្រវត្ត ស្ថិតក្នុងស្ថានភាពធ្វើការជំរះបញ្ជី ។

១-២ ផុតរយៈពេលមួយឆ្នាំ បើក្រសួង ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស និងបានសំណូម បញ្ចូលអង្គភាពក្រោមការគ្រប់គ្រងរបស់ខ្លួនចូលក្នុងវិធានណាមួយ ដូចចែងក្នុងវាក្យខ័ ១.១ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំសំណើផ្ទាល់ទៅរាជរដ្ឋាភិបាល ។

១-៣ ចំពោះអង្គភាពឧស្សាហកម្ម និងពាណិជ្ជកម្មរបស់រដ្ឋ ដែលពុំមាននីតិបុគ្គលភាពគតិយុ របស់រដ្ឋ -អង្គភាពសាធារណៈ និងសហគ្រាសដែលជាភាគកម្មជាកម្មសិទ្ធិរបស់រដ្ឋ ហើ ដែលស្ថិតក្នុងសេចក្តីសំរេចរបស់គណៈរដ្ឋមន្ត្រីសំរាប់ធ្វើឯកជនភាវូបនីយកម្មនោះក្នុងករណី បាច់អាចរក្សាទុកនូវលក្ខន្តិកៈគតិយុត្តបច្ចុប្បន្នរបស់ខ្លួនសិនមុនដល់ពេលរៀបចំដំណើរការ ឯកជនភាវូបនីយកម្ម

មាត្រា ២ -

ក្នុងនាមជានីតិបុគ្គលស្វយ័ត សហគ្រាសសាធារណៈទាំងឡាយ ត្រូវមានលក្ខណៈសម្ ដូចតទៅ :

១- មាននាមករណ៍ និងទីស្នាក់ការរបស់ក្រុមហ៊ុន

២- មានកម្មវត្ថុច្បាស់លាស់របស់ក្រុមហ៊ុន

៣-មានក្រុមប្រឹក្សាភិបាល និងការគ្រប់គ្រងដោយឡែក

៤- មានថវិកាផ្ទាល់

៥- មានទ្រព្យសម្បត្តិសំរាប់ធ្វើសកម្មភាព ដូចមានគ្រោងទុកក្នុងកម្មវត្ថុរបស់ក្រុមហ៊ុន

៦- មានសមត្ថភាពចុះកិច្ចសន្យា និងប្តឹង ឬការពារនៅតុលាការ

២២.៤.វិធានការទាំងឡាយដែលមានចែងខាងលើនេះ មិនមែនជាឧបសគ្គរាំងមិនឱ្យអនុវត្តប
បញ្ញត្តិនៃច្បាប់ និងបទបញ្ជាស្តីពីឯកជនភាវូបនីយកម្មសហគ្រាស និងទ្រព្យសកម្មរបស់
រដ្ឋទេ ។

ជំពូក៣

បទបញ្ញត្តិដោយឡែកសំរាប់ប្រភេទផ្សេងៗនៃសហគ្រាសសាធារណៈ

ផ្នែកទី១ : គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច

មាត្រា ២៣.ការរៀបចំ និងការប្រព្រឹត្តិទៅ បុព្វសិទ្ធ និងអំណាចរបស់ គ.ស.ស ត្រូវកំណត់ដោយ:

-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងបទបញ្ញត្តិទាំងឡាយស្តីពីការអនុវត្តន៍ព្រះរាជក្រមនេះ ។

-អនុក្រឹត្យស្តីពីការបង្កើតសហគ្រាសសាធារណៈ និងលក្ខន្តិកៈដែលជាឧបសម្ព័ន្ធ៣ និង បទបញ្ញត្តិនៃច្បាប់ និងបទបញ្ជា អនុវត្តសំរាប់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលមិនផ្ទុយនឹង អត្ថបទដែល ចែងខាងលើ ជាពិសេសស្តីពីទំនាក់ទំនង គ.ស.ស ជាមួយតតិយជន ។

មាត្រា ២៤. លក្ខន្តិកៈនៃ គ.ស.ស ត្រូវបានរៀបចំឡើងដោយក្រសួងអាណាព្យាបាលបច្ចេកទេស សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយត្រូវភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងអនុក្រឹត្យ ស្តីពី ការបង្កើតសហគ្រាសនេះ ។

មាត្រា ២៥.. គ.ស.ស អាចចាត់ទុកត្រូវបានបង្កើតចាប់ពីថ្ងៃចុះហត្ថលេខាលើអនុក្រឹត្យ ។ ដំណើរការ អនុវត្តន៍នឹងអាចប្រព្រឹត្តទៅបាន បន្ទាប់ពីការតែងតាំងសមាជិកប្រធាន នៃក្រុមប្រឹក្សា ភិបាល និង អគ្គនាយក ។

មាត្រា ២៦.. មូលធនរបស់ គ.ស.ស អាចចែកចេញជាភាគទុនជារូបិយវត្ថុ និងភាគទុនជាចលនៈ និង អចលនៈទ្រព្យ ។ ភាគទុនជាចលនៈនិងអចលនៈទ្រព្យត្រូវវាយតំលៃដោយគណៈកម្មការ វាយតំលៃមួយ ដែលរួមមានសមាជិកចាត់តាំងដោយរដ្ឋមន្ត្រី ក្រសួងអាណាព្យាបាល បច្ចេកទេស និងរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ២៧.. ប្រតិបត្តិការហិរញ្ញវត្ថុទាំងឡាយរបស់រដ្ឋក្នុងឋានៈជាម្ចាស់ភាគហ៊ុននិង គ.ស.សត្រូវអនុ លោមតាមបញ្ញត្តិចែងដោយព្រះរាជក្រមលេខ ១នស/៩៣ ចុះថ្ងៃទី២៨ ធ្នូ ឆ្នាំ១៩៩៣ ស្តីពី ប្រព័ន្ធច្បាប់ហិរញ្ញវត្ថុ និងលិខិតបទដ្ឋានបន្តបន្ទាប់ក្រោយៗទៀត ។ កិច្ចការនេះតម្រូវ :

១-ភាគទុនជាមូលធនចាប់ពីពេលបង្កើត ឬក្រោយការបង្កើត គ.ស.ស ត្រូវបានគ្រោងទុ
អនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុដោយចាត់ទុកជាចំណាយលើការវិនិយោគរបស់រដ្ឋក្នុងកិច្ចប្រ
តិបត្តិការហិរញ្ញវត្ថុ ។

២- ចំណូលដែលរដ្ឋបានមកពី គ.ស.ស គឺជាប្រភពចំណូលថវិកា :

- (I) ទុកជាចំណូលមូលធនក្នុងប្រទេស ក្នុងករណីលក់ គ.ស.ស

- (II) ឬទុកជាចំណូលនៃទ្រព្យសម្បត្តិរដ្ឋ ក្នុងករណីជាប្រាក់ចំណេញតាមភាគហ៊ុន ។

ជំពូកទី២ : ក្រុមហ៊ុនរដ្ឋ

មាត្រា ២៨.- ការរៀបចំ និងការប្រព្រឹត្តិទៅ បុព្វសិទ្ធ និងអំណាចរបស់ ក្រ.រ ត្រូវកំណត់ដោយៈ

-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ១៩៩៦ និងបញ្ញ
ទាំងឡាយស្តីពីការអនុវត្តនីព្រះរាជក្រមនេះ ។

-អនុក្រឹត្យស្តីពីការបង្កើតសហគ្រាសសាធារណៈ និងលក្ខន្តិកៈដែលជាឧបសម្ព័ន្ធ៣ និងប
បញ្ញត្តិនៃច្បាប់និងបទបញ្ជា អនុវត្តសំរាប់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលមិនផ្ទុយនឹងអត្ថប
ដែលចែងខាងលើ ជាពិសេសស្តីពីទំនាក់ទំនង គ.ស.ស ជាមួយតតិយជន ។

មាត្រា ២៩.- លក្ខន្តិកៈរបស់ ក្រ.រ ត្រូវរៀបចំឡើងដោយ ក្រសួងអាណាព្យាបាលបច្ចេកទេសសហក
ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣០.-

៣០.១.-ទំរង់នៃការបង្កើត ក្រ.រ ត្រូវប្រព្រឹត្តដោយអនុលោមទៅតាមវិធាននៃនីតិក្រុមហ៊ុ
ពាណិជ្ជកម្មដោយអណត្តិអគ្គាហកៈម្នាក់ ដែលជ្រើសរើសដោយរដ្ឋមន្ត្រីក្រសួង អាណាព្យ
បាលបច្ចេក ទេសហើយដែលជាអ្នក :

- ដាក់លក្ខន្តិកៈរបស់ក្រ.រ ជូនរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួ
សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះហត្ថលេខារួម

- ចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម និងក្រុមហ៊ុនជារួមគឺបំពេញបែបបទចាំបាច់ផ្សេង
តាមនីតិក្រុមហ៊ុនពាណិជ្ជកម្ម ។

៣០.២.ក្រ.រអាចមាននីតិបុគ្គលចាប់ពីថ្ងៃចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ។ ចន្លោះថ្ងៃ
ចេញអនុក្រឹត្យបង្កើត និងថ្ងៃចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុនមិនអាចសំរេចកិច្ចក
អ្វីមួយបានទេ លើកលែងតែកិច្ចការដែលសំរេចដោយអាណត្តិគាហកៈរបស់រដ្ឋមន្ត្រីក្រសួ
អាណាព្យាបាល បច្ចេកទេស ។

ចាត់ឱ្យធ្វើជាលេខាធិការនៃអង្គប្រជុំ ។ កំណត់ហេតុនេះ នឹងត្រូវបញ្ជូនទៅសមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងពេល១០ថ្ងៃយ៉ាងយូរបន្ទាប់ពីការប្រជុំ ។ ខ្លឹមសារកំណត់ហេតុត្រូវឆ្លុះបញ្ចាំងឱ្យបាន ត្រឹមត្រូវនៃសេចក្តីនៃការជជែកពិភាក្សា ។ ក្នុងករណីមានយោបល់ជំទាស់របស់សមាជិកក្រុមប្រឹក្សា ភិបាលសំរាប់ការប្រជុំលើកក្រោយត្រូវកត់ត្រានូវយោបល់នោះក្នុងកំណត់ហេតុនេះ ។

ប្រការ ៩_

៩_១_សមាសភាពនៃក្រុមប្រឹក្សាភិបាលនៃ **គ.ស.ស** និង **ក្រ.រ** អាចរៀបចំតាមរូបមន្តមួយក្នុងចំណោម រូបមន្តពីរដូចតទៅ :

១- ត្រូវមានតែតំណាងរបស់រដ្ឋដែលជាម្ចាស់កម្មសិទ្ធិ ឬជាម្ចាស់ភាគហ៊ុន

២- ត្រូវបែងចែកសមាជិកក្រុមប្រឹក្សាភិបាលជាពីរប្រភេទ : (I) តំណាងរបស់រដ្ឋដែលជាម្ចាស់កម្មសិទ្ធិ ឬម្ចាស់ភាគហ៊ុន (II) តំណាងរបស់ធុរៈជន ពាណិជ្ជករ និង ឬអ្នកប្រើប្រាស់ ។ ក្នុងករណីនេះ តំណាងរបស់រដ្ឋត្រូវឱ្យមានចំនួនភាគច្រើននៅក្នុងក្រុមប្រឹក្សាភិបាល ។ តំណាងរបស់ធុរៈជន ពាណិជ្ជករ ឬអ្នកប្រើប្រាស់ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់អង្គការដែល ជាតំណាងរបស់ខ្លួន (សភាពាណិជ្ជកម្ម សមាគមមុខរបរ សមាគមអ្នកប្រើប្រាស់ ។ល។)

៩_២_ម្ចាស់ភាគហ៊ុនសាធារណៈ ជានិច្ចត្រូវមានចំនួនភាគច្រើននៃអសនៈរបស់ក្រុមប្រឹក្សាភិបាលក្នុង **ក្រ.ច** ដែលមានភាគកម្មសាធារណៈចំនួនភាគច្រើន ។

ប្រការ ១០_ អ្នកតំណាងរបស់និយោជិត នឹងត្រូវបានជ្រើសតាំងជាសមាជិកស្វ័យប្រវត្តិនៃក្រុមប្រឹក្សាភិបាល ។ អនុក្រឹត្យស្តីពីការបង្កើត **គ.ស.ស** ឬ **ក្រ.រ** និង **ក្រ.ច** ដែលមានភាគកម្មសាធារណៈចំនួនភាគច្រើនអាចគ្រោងនូវ សមាជិកស្វ័យប្រវត្តផ្សេងទៀតក្នុងក្រុមប្រឹក្សាភិបាល ។ សមាជិកស្វ័យប្រវត្តិអាចចូលបំពេញការងារក្នុងក្រុមប្រឹក្សាភិបាល ចាប់ពីថ្ងៃដែលខ្លួនត្រូវបានជ្រើសតាំង ឬត្រូវបានតែងតាំងក្នុងមុខងារ ដែលតម្រូវឱ្យចូលរួមក្នុងក្រុមប្រឹក្សាភិបាល ដោយ ពុំចាំបាច់មានការតែងតាំងដោយអនុក្រឹត្យឡើយ ។

ការចប់អាណត្តិនៃការជ្រើសតាំងឬការបាត់បង់មុខងាររបស់សមាជិកគតិយុត្តិនឹងត្រូវបញ្ចប់ការចូលរួមរបស់អ្នកទាំងនោះក្នុងក្រុមប្រឹក្សាភិបាលតាមផ្លូវច្បាប់ជាស្វ័យប្រវត្តិ ។

មាត្រា១១.

១១.១-សមាជិកក្រុមប្រឹក្សាភិបាល ដែលជាតំណាងនិយោជិត ត្រូវជ្រើសតាំងក្នុងរយៈពេល ៣ ឆ្នាំយ៉ាងយូរតាមការកំនត់របស់ក្រុមប្រឹក្សាភិបាល ។ អាណត្តិនេះអាចបន្តទៀតបាន ។

- សមាជិកស្វ័យប្រវត្តិ អាចរក្សាតំណែងជាសមាជិកក្រុមប្រឹក្សាភិបាលតែក្នុងរយៈពេលពេញ ការងារតែប៉ុណ្ណោះ ។

អាណត្តិរបស់ក្រុមប្រឹក្សាភិបាលផ្សេងទៀត មានរយៈពេល ៣ឆ្នាំ ។ អាណត្តិនេះអាចបន្តទៀតបាន ។

១១.២-សមាជិកក្រុមប្រឹក្សាភិបាល លើកលែងតែសមាជិកដែលតំណាងនិយោជិត មិនមែនបុគ្គលិក សហគ្រាសទេដូចនេះមិនអាចបើកប្រាក់បៀវត្សបានទេ ។ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកសំរេចរួមជាគោលការណ៍ចំពោះលាភការសំរាប់មុខងារជាសមាជិកក្រុមប្រឹក្សាភិបាល កំណត់ទឹកប្រាក់នៃប្រាក់លាភការដែលត្រូវផ្តល់ជូន ។ ការបើកលាភការអាចត្រូវផ្អាកដោយអាជ្ញាធរ ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាអ្នក តំណាងឱ្យ ចំពោះគ្រប់សមាជិកដែលពុំបានគោរពនូវកាតព្វកិច្ចក្នុងអាណត្តិរបស់ខ្លួន :

(I) ឧស្សាហ៍ព្យាយាម

(II) គោរពបទបញ្ញត្តិច្បាប់ បទបញ្ជា និងលក្ខន្តិកៈរបស់សហគ្រាស

(III) ការពារនយោបាយនិងផលប្រយោជន៍របស់អាជ្ញាធរ ដែលជាអ្នកចាត់តាំងអាណត្តិ ឱ្យខ្លួន

(IV) កាតព្វកិច្ចរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន ។

មាត្រា១២. ប្រធានអគ្គនាយកជាអ្នកតំណាងស្របច្បាប់របស់សហគ្រាស ក្នុងការធ្វើទំនាក់ទំនងជាមួយតតិយជន ។ ក្នុងករណីដែលការដឹកនាំ ត្រូវបានប្រគល់ឱ្យអគ្គនាយក គឺអគ្គនាយកហើយដែលជាតំណាងស្របច្បាប់របស់សហគ្រាស ក្នុងការធ្វើទំនាក់ទំនងជាមួយតតិយជន។

មាត្រា១៣. ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ប្រធានអគ្គនាយក ឬអគ្គនាយក ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវគំរោងថវិកា និងគំនូសបំព្រួញហិរញ្ញប្បទាន ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលឯកសារក្នុងរយៈពេល១ខែ ត្រូវរៀបចំផ្តល់យោបល់របស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួង អាណាព្យាបាលបច្ចេកទេស។ រដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេក ក្នុងរយៈពេល២ខែ ចាប់ពី ថ្ងៃទទួលឯកសារពីប្រធានអគ្គនាយក ឬអគ្គនាយកត្រូវបញ្ជូន

យល់ព្រមឬជំទាស់លើឯកសារទាំងនេះ ។ លិខិតយល់ព្រម ត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស ឬ តំណាងហើយត្រូវផ្ញើទៅជូនប្រធានអគ្គនាយក ឬអគ្គនាយកព្រមទាំងចំលងជូនរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ប្រធានអគ្គនាយក ឬនាយកត្រូវជូន ពត៌មានពីបញ្ហានេះទៅក្រុមប្រឹក្សាភិបាលឱ្យបានទាន់ពេលវេលានិងដាក់អនុវត្តគំរោងថវិកា ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេក ទេស មិនបានឆ្លើយតបតាមពេលកំណត់ទេនោះ គំរោងថវិកានេះត្រូវចាត់ទុកថាត្រូវបានយល់ព្រមហើយ ប្រធានអគ្គនាយក ឬអគ្គនាយក យកគំរោងថវិកានេះទៅអនុវត្ត ។ ប្រសិនបើក្រសួងអាណាព្យាបាលបច្ចេកទេស មានការជំទាស់លើគំរោងថវិកា ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀប [illegible] ទាស់នោះ ។ គំរោងថវិការបស់សហគ្រាស នឹងមិនអាចដាក់អនុវត្តបាន ដរាបណាមានការជំទាស់ពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស ។

មាត្រា១៤- រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស អាចបង្ហាញការជំទាស់របស់ខ្លួនលើឯកសារដែលត្រូវបានផ្ញើមកជូនដូចមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមគឺ : (I) កំណត់ហេតុនៃការប្រជុំនានារបស់ក្រុមប្រឹក្សាភិបាល (II) តារាងហិរញ្ញវត្ថុនិងរបាយការណ៍សកម្មភាព (III) របាយការណ៍នៃការផ្ទៀងផ្ទាត់គណនី ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសរៀបចំធ្វើការជំទាស់ក្នុងអំឡុងពេល ១ខែ ចាប់ពីថ្ងៃ ទទួលឯកសារមក ។ក្នុងករណីដែលរដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស មិនបានឆ្លើយតប តាមពេល វេលាកំណត់ដែលបាន ផ្ញើមកជូនដោយក្រុមប្រឹក្សាភិបាល ត្រូវចាត់ទុកថាពុំមានការជំទាស់ ហើយ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលអាចដាក់អនុវត្តបាន ។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេសបង្ហាញការជំទាស់ ក្រុមប្រឹក្សាភិបាល ត្រូវរៀបចំធ្វើការពិភាក្សាជាបន្ទាន់ ដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ ។ ក្នុងករណីដែលក្រុមប្រឹក្សាភិបាលសំរេច ពុំយកជាការនូវការជំទាស់នោះ ត្រូវមានមូលហេតុ ហើយត្រូវជូនដំណឹងពីការសំរេចនេះ ជាលាយល័ក្ខអក្សរដល់ រដ្ឋមន្ត្រីអាណាព្យាបាល ។ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលនេះអាចដាក់អនុវត្តបន្ទាន់ ។

មាត្រា ១៥-

១៥-១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងនាមជាតំណាងរបស់រដ្ឋមានបេសកកម្មពីរគឺធ្វើការតាមដាន និងការត្រួតពិនិត្យលើសហគ្រាសសាធារណៈ ។ បេសកកម្មនេះ ត្រូវប្រគល់

ទៅឱ្យមន្ត្រីរាជការមួយរូប ដែលមានឈ្មោះថាមន្ត្រីត្រួតពិនិត្យរដ្ឋដូចមានចែងក្នុង មាត្រ
នៃក្រម ។

១៥-២-មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបានតែងតាំង និងត្រូវដកចេញពីដំណែងវិញដោយអនុក្រឹត្យ សំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបានជ្រើស ក្នុងចំណោមមន្ត្រីជាន់ខ្ពស់របស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបាននិងកំពុងបំពេ ងារសាធារណៈយ៉ាងតិច៥ឆ្នាំ ។

១៥-៣-មន្ត្រីត្រួតពិនិត្យរដ្ឋ បំពេញមុខងាររបស់ខ្លួននៅក្រោមបញ្ជានិងការណែនាំរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុហើយត្រូវរាយការណ៍ជាទៀងទាត់ ពីកិច្ចការដែលបានអ ដូចនេះមន្ត្រីត្រួតពិនិត្យរដ្ឋត្រូវផ្តល់ជូនរដ្ឋមន្ត្រីក្នុងមួយត្រីមាសម្តងនូវរបាយការណ៍លំអិត ដំណើរ ការនិងលទ្ធផលនៃសហគ្រាសដែលខ្លួនពិនិត្យ ។ សេចក្តីចំលងរបាយការណ៍មួយ អាចផ្ញើទៅជូនរដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស ប្រសិនបើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុយល់ថាជាការចាំបាច់ ។ តាមរយៈរបាយការណ៍នេះមន្ត្រីត្រួតពិនិត្យរដ្ឋត្រ ពត៌មានជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសុំការណែនាំនូវរាល់ បេសកក ពិនិត្យរបស់ខ្លួន ។

១៥-៤-ដើម្បីបំពេញបេសកកម្មរបស់ខ្លួន មន្ត្រីត្រួតពិនិត្យរដ្ឋអាចស្នើសុំពត៌មានឬធ្វើការស្ទ នៅនឹងកន្លែងលើគ្រប់ឯកសារ កិច្ចសន្យាអនុសញ្ញាកំណត់សំណេរដែលក្នុងរបាយការណ៍ និង បញ្ជី គណនេយ្យ ហើយត្រូវរក្សាការសំងាត់របស់សហគ្រាស ។

១៥-៥-មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបានទទួលលាភការក្នុងល័ក្ខខ័ណ្ឌដូចគ្នានៃមាត្រា១១-២ សំរាប់សមាជិក ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៦-

១៦-១-មន្ត្រីត្រួតពិនិត្យរដ្ឋទទួលបន្ទុកតាមដានជាប្រចាំនូវការប្រព្រឹត្តទៅរបស់សហគ្រាស និ ពត៌មានជូនអាជ្ញាធរព្យាបាល ជាពិសេសលើស្ថានភាពហិរញ្ញវត្ថុ ។

១៦-២-បេសកកម្មតាមដានរបស់មន្ត្រីត្រួតពិនិត្យរដ្ឋជាក់ស្តែង មានការតាមដានជាប្រ សកម្មភាពរបស់សហគ្រាស និងការចូលរួមយ៉ាងសកម្មស្ទិតស្ថាញក្នុងការងាររបស់អ គ្រប់គ្រងរបស់សហគ្រាស ។

មន្ត្រីត្រួតពិនិត្យរដ្ឋមានសិទ្ធិចូលរួមនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។ មន្ត្ ពិនិត្យរដ្ឋត្រូវបានកោះអញ្ជើញ និងត្រូវបានផ្តល់ឯកសារដែលនឹងត្រូវពិនិត្យដោយ

ប្រឹក្សាភិបាលក្នុងឋានៈដូចសមាជិកក្រុមប្រឹក្សាភិបាលដែរ ។ មន្ត្រីត្រួតពិនិត្យរដ្ឋអាចមានយោបល់ លើបញ្ហាដែលមានចុះក្នុងរបៀបវារៈ ប៉ុន្តែពុំអាចចូលរួមក្នុងការបោះឆ្នោតទេ ជាពិសេស ត្រូវផ្ដល់មតិរបស់ខ្លួនជូនក្រុមប្រឹក្សាភិបាលក្នុងការធ្វើគំរោងថវិកា និងគណនីប្រចាំឆ្នាំ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានអញ្ជើញចូលរួមក្នុងមហាសន្និបាតហើយអាចឡើងមានមតិនិងផ្ដល់យោបល់លើបញ្ហាដែលមានក្នុងរបៀបវារៈ ។

១៦-៣-មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវទំនាក់ទំនងការងារយ៉ាងជិតស្និទ្ធជាមួយនឹងអគ្គនាយកដ្ឋាន និងក្រុមប្រឹក្សាភិបាលហើយត្រូវចូលរួមផ្ដល់យោបល់ និងជួយសហគ្រាសក្នុងករណីចាំបាច់លើបញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។

ប្រការ ១៧-

១៧-១-មន្ត្រីត្រួតពិនិត្យរដ្ឋ ទទួលបន្ទុកត្រួតពិនិត្យប្រក្រតីនីតិភាពនៃសេចក្ដីសំរេច របស់ក្រុមប្រឹក្សា ភិបាលហើយមានអំណាចធ្វើការជំទាស់ដល់ការប្រតិបត្តិនៃសេចក្ដីសំរេចនោះ ។

អំណាចធ្វើការជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋ ពុំប៉ះពាល់ទៅលើកិច្ចគ្រប់គ្រងរបស់ប្រធានអគ្គនាយកឬអគ្គនាយកទេ ។ អំណាចជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋអាចធ្វើភ្លាម១ក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលឬយ៉ាងយូរក្នុងអំឡុង៣ថ្ងៃបន្ទាប់ពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។ អំណាចជំទាស់មានលក្ខណៈជាការត្រួតពិនិត្យប្រក្រតីនីតិភាព គឺពុំមែនត្រួតពិនិត្យកាលានុវត្តភាពនៃសេចក្ដីសំរេចចិត្តទេ ។

១- កម្មវត្ថុរបស់សហគ្រាស

២- ភារកិច្ចរបស់សហគ្រាសលើការអនុវត្តបទបញ្ញត្តិនិងបទបញ្ជាជាធរមាន លក្ខន្តិកៈរបស់សហគ្រាស ឬសេចក្ដីសំរេចរបស់រដ្ឋាភិបាល ។

៣- សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល ដែលមានពីមុនមក ។

១៧-២-ការជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវជូនដំណឹងទៅក្រុមប្រឹក្សាភិបាលតាមរបៀបពីរយ៉ាងៈ

- ដោយផ្ទាល់មាត់ក្នុងពេលប្រជុំ ៖ ក្នុងករណីនេះ ការជំទាស់ត្រូវកត់ត្រាក្នុងកំណត់ហេតុនៃអង្គប្រជុំ ។

ឬក្នុងរយៈពេល៣ថ្ងៃ ធ្វើការក្រោយប្រជុំ ៖ ក្នុងករណីនេះ ការជំទាស់ត្រូវតែធ្វើឡើងជាលាយលក្ខអក្សរ ហើយផ្ញើជូនប្រធានក្រុមប្រឹក្សាភិបាល ។

១៧-៣-ការជំទាស់នេះត្រូវមានការយល់ស្របពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរដ្ឋមន្ត្រីរ
ព្យាបាលបច្ចេកទេស ក្នុងរយៈពេល៤ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃសំដែងចេញនូវការជំទាស់ ។

លើសពីរយៈពេលកំណត់ ប្រសិនបើពុំមានការបញ្ជាក់បន្ថែមនេះទេ ការសំរេចរបស់
ប្រឹក្សាភិបាលនឹងត្រូវអនុវត្តជាបន្ទាន់ ។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬរដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស
ស្របលើការជំទាស់ដោយលិខិតបដិសេធ ឬដោយធ្វើការកែសំរួលសេចក្ដីសំរេចចិត្តពា
នោះ សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាលពុំអាចអនុវត្តបានឡើយ ។ ក្នុងករណីនេះ ប្រ
ក្រុមប្រឹក្សាភិបាលត្រូវរៀបចំប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់បំផុតដើម្បីធ្វើការសំរេច
ក្រុមប្រឹក្សាភិបាលអាចបដិសេធនូវសេចក្ដីសំរេចរបស់ខ្លួន ឬមួយធ្វើការកែសំរួលតាមសំ
ពរអាជ្ញាធរអាណាព្យាបាល ។ ក្នុងករណីទីពីរក្រោយនេះ សេចក្ដីសំរេចអាចអនុវត្តជាប
បាន ។

មាត្រា ១៨- គណនីប្រចាំឆ្នាំរបស់សហគ្រាសសាធារណៈ ត្រូវជាកម្មវត្ថុនៃការផ្ទៀងផ្ទាត់ និងការ បញ
របស់ស្នងការគណនី ។

ស្នងការគណនីត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាភិបាលដែលជាអ្នកកំណត់លាភការដែ
ត្រូវផ្ដល់ជូនស្នងការគណនីនេះផងដែរ ។ ការជ្រើសរើសនេះត្រូវធ្វើលើបញ្ជីនៃរូបវន្តបុគ្គ
នីតិបុគ្គលដែលមានសញ្ជាតិកម្ពុជា និងមានការយល់ព្រមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រ
សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការតែងតាំងស្នងការគណនី ធ្វើឡើងតាមសេចក្ដីសំរេចរបស់រដ្ឋមន្ត្រីក្រសួងសេ
និងហិរញ្ញវត្ថុ ក្នុងអាណត្តិដែលអាចបន្តជាថ្មីបន្ថែមលើពាក្យបរិច្ឆេទនៃសហគ្រាស ។

ស្នងការគណនីបំពេញបេសកកម្មទៅតាមបែបផែន
ដែលកំណត់ដោយអនុក្រឹត្យតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ១៩-

១៩-១-ភាគកម្មរបស់រដ្ឋដែលរួមមាន **គ.ស.ស ក្រ.៛** និងភាគកម្ម **ក្រ.ច** ត្រូវគ្រប់
ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាលបច្ចេកទេស ។

ភាគកម្មរបស់ **គ.ស.ស.ក្រ.៛** និងរបស់ **ក្រ.ច** ដែលភាគកម្មសាធារណៈជាចំនួ
ច្រើននៅក្នុងដើមទុនរបស់ **ក្រ.ច** ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលរបស់អង្គភា

នេះ ។ មុនពេលសំរេចធ្វើការទិញភាគកម្មក្នុងក្រុមហ៊ុនចំរុះ ក្រុមប្រឹក្សាភិបាលទាំងនេះ ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាលបច្ចេកទេស ។

១៩-២-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាត់ចែងភាគកម្មផ្ទាល់របស់រដ្ឋក្នុងល័ក្ខខ័ណ្ឌដូចតទៅ :

១- វាយតំលៃកាលានុវត្តភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃការបង្កើត **គ,ស,ស** និង **ក្រ,រ** ធ្វើភាគកម្មក្នុង **ក្រ,ច**

២-អនុវត្តឱ្យបានសំរេចនូវប្រតិបត្តិការប្រមូលភាគទុនជាសាច់ប្រាក់ ឬជាវត្ថុ ឬការធ្វើលទ្ធកម្មភាគហ៊ុនដោយអនុលោមតាមទិសដៅដែលបានសំរេចដោយរាជរដ្ឋាភិបាល និងតាមបទបញ្ញត្តិនៃច្បាប់ និងបទបញ្ជានានាស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋ ។

៣- កាន់កាប់រក្សាទុកនូវមូលប័ត្រដែលតំណាងភាគកម្មសរុបរបស់រដ្ឋ ។

៤- ភ្ជាប់ឱ្យបានជាប្រចាំនូវពត៌មានចាំបាច់សំរាប់ធ្វើការតាមដានលើដំណើរការ និងលើការផ្តល់ផលរបស់សហគ្រាសសាធារណៈ

៥- ចូលរួមជាមួយក្រសួងអាណាព្យាបាលបច្ចេកទេសក្នុងការរៀបចំផែនការធ្វើនីតិសម្បទា និងរៀបចំរចនាសម្ព័ន្ធសហគ្រាសសាធារណៈឡើងវិញ
ហើយត្រូវធ្វើការតាមដានលើការ អនុវត្ត

៦- ចូលរួមជាមួយក្រសួងអាណាព្យាបាលបច្ចេកទេស ក្នុងការកាត់តែងនូវគោលនយោបាយសំរាប់ទំនាក់ទំនងលើកិច្ចសន្យារវាងរដ្ឋជាមួយសហគ្រាសសាធារណៈ
ហើយត្រូវធ្វើការតាម ដានការអនុវត្តន៍ ។

មាត្រា ២០-ប្រធានអគ្គនាយក ឬអគ្គនាយកនៃ **គ,ស,ស** **ក្រ,រ** ឬ **ក្រ,ច** ដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ត្រូវមានសញ្ជាតិខ្មែរ និងត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងអាណាព្យាបាលបច្ចេកទេស ដោយឈរជាពិសេសលើលក្ខណៈវិនិច្ឆ័យនៃសមត្ថភាពនិងការពិសោធន៍ ។

មាត្រា ២១-គ្រប់ការរំលាយបញ្ចូលគ្នា ការបំបែក ឬការជំរះបញ្ជីនៃ **គ,ស,ស** ឬ **ក្រ,រ** ត្រូវធ្វើឡើងដោយអនុក្រឹត្យ តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រោយមានការ ផ្តល់យោបល់ពីក្រុមប្រឹក្សាភិបាលរបស់សហគ្រាសពាក់ព័ន្ធ ។

-គ្រប់ការរំលាយបញ្ចូលគ្នា ការបំបែក ឬការជំរះបញ្ជីនៃ **ក្រ,ច** ដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើនត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិង

ក្រោយមានការផ្តល់យោបល់ពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងពីក្រុម
ភិបាលរបស់សហគ្រាសពាក់ព័ន្ធ ។

-គ្រប់ការរំលាយបញ្ចូលគ្នា ការបំបែក ឬការជំរះបញ្ជីនៃ គ្រ,ខ ដែលមានភា
សាធារណៈ ជាចំនួនភាគហ៊ុនតិច ត្រូវធ្វើឡើងតាមទំរង់បែបបទដែលមានកំណត់ក្នុងល
របស់ក្រុមហ៊ុន ។

មាត្រា ២២-

២២-១-អនុប្បទាននៃ **គ,ស,ស** ឬការលក់ភាគហ៊ុនរបស់ **គ្រ,ក** ត្រូវមានការអនុញ្ញាត
អនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រី
សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោយមានការផ្តល់យោបល់ពីក្រុមប្រឹក្សាភិបាលរបស់សហ
ពាក់ព័ន្ធ ។

២២-២-អនុប្បទាននៃភាគហ៊ុនរបស់រដ្ឋក្នុង **គ្រ,ខ** ដែលមានភាគកម្មសាធារណៈ ជាចំនួ
ច្រើនត្រូវមានការអនុញ្ញាតដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោយ
ការផ្តល់យោបល់ពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងក្រុមប្រឹក្សាភិបាល
សហគ្រាសពាក់ ព័ន្ធ ។

អនុប្បទាននៃភាគហ៊ុនរបស់ **គ,ស,ស** ឬ **គ្រ,ក** នៅក្នុង **គ្រ,ខ** ណាមួយ
មានភាគកម្មភាពសាធារណៈជាចំនួនភាគច្រើន ត្រូវមានការយល់ព្រមពីក្រសួងអ
ព្យាបាលបច្ចេក ទេសនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិ
ដែលជាតំណាង ម្ចាស់ភាគហ៊ុន ។

២២-៣-អនុប្បទាននៃភាគហ៊ុនរបស់រដ្ឋនៅក្នុង**គ្រ,ខ**ដែលមានភាគកម្មសាធារណៈជាចំនួនភាគ
ត្រូវសំរេចឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានកា
យោបល់ពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស ។

អនុប្បទាននៃភាគហ៊ុនរបស់ **គ,ស,ស** ឬ **គ្រ,ក** នៅក្នុង **គ្រ,ខ** ដែលមានភា
សាធារណៈជាចំនួនភាគតិចត្រូវមានការយល់ព្រមពីក្រសួងអាណាព្យាបាលបច្ចេកទេស
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដែលជាតំណាង
ភាគហ៊ុន ។

មាត្រា ៣១.-

៣១.១.- មូលធនរបស់ក្រុមហ៊ុន អាចបែងចែកជាភាគទុនជារូបិយវត្ថុ និងភាគទុនជាចលនៈ និង អចលនៈទ្រព្យ ។

ភាគទុនជាចលនៈ និងអចលនៈទ្រព្យត្រូវបានវាយតំលៃដោយគណៈកម្មការវាយតំលៃមួយរួមមានសមាជិកចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាល បច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៣១.២.- មូលធនរបស់ក្រុមហ៊ុនត្រូវបែងចែកជាភាគហ៊ុនដែលមានចុះឈ្មោះម្ចាស់ភាគហ៊ុន ហើយត្រូវចុះបញ្ជីទាំងស្រុងនៅពេលបង្កើត **ក្រ.ស** ។

ភាគហ៊ុនត្រូវបានបង់ចូលក្នុងល័ក្ខខ័ណ្ឌដែល បានកំណត់ដោយនីតិក្រុមហ៊ុនពាណិជ្ជកម្មលើកលែងតែមានបទបញ្ញត្តិដោយឡែកដែល ចែងក្នុងអនុក្រឹត្យស្តីពីការបង្កើត **ក្រ.ស**។

ការបង់ចូលនូវភាគហ៊ុនជារូបិយវត្ថុ ត្រូវបានទទួលដោយប័ណ្ណចំណូលមួយរៀបចំដោយអាណាព្យាបាលបច្ចេកទេស ។ អាណត្តិគាហកៈរបស់រដ្ឋមន្ត្រីក្រសួងអាណាព្យា បាលបច្ចេកទេស ។ អាណត្តិគាហកៈត្រូវយកមូលនិធិទៅតំកល់ទុកក្នុងគណនីមួយនៅធនាគារជាតិឬនៅធនាគារជាតិនៃកម្ពុជា ។ ទុនទាំងនេះមិនអាចប្រើមុនពេលចុះបញ្ជីក្រុមហ៊ុននៅ ក្នុងបញ្ជីពាណិជ្ជកម្មបានឡើយ ។

ការបង់ចូលនូវភាគហ៊ុនជាចលនៈ និង អចលនៈទ្រព្យ ត្រូវមានធ្វើបញ្ជីសារពើភ័ណ្ឌដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួង អាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវភ្ជាប់ជា ឧបសម្ព័ន្ធជាមួយលក្ខន្តិកៈ **ក្រ.ស** ។

មាត្រា ៣២.- ប្រតិបត្តិការហិរញ្ញវត្ថុទាំងឡាយរបស់រដ្ឋ ក្នុងឋានៈជាម្ចាស់ភាគហ៊ុនជាមួយ **ក្រ.ស** ត្រូវតែអនុលោមតាមបទបញ្ញត្តិដែលចែងដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីប្រព័ន្ធច្បាប់ហិរញ្ញវត្ថុ និងលិខិតបទដ្ឋានបន្តបន្ទាប់ក្រោយៗទៀត ។ កិច្ចការ នេះគឺៈ

- ភាគទុនជាមូលធនចាប់ពីពេលបង្កើត **ក្រ.ស** ឬក្រោយការបង្កើតត្រូវបានគ្រោង និង អនុញ្ញាត ដោយច្បាប់ហិរញ្ញវត្ថុដោយចាត់ទុកចំណាយលើការវិនិយោគរបស់រដ្ឋក្នុងកិច្ចជាប្រតិបត្តិការ ហិរញ្ញវត្ថុ
- ចំណូលដែលរដ្ឋបានមកពី **ក្រ.ស** គឺជាប្រភពចំណូលថវិកា :

(I)-ទុកជាចំណូលមូលធនក្នុងប្រទេស ក្នុងករណីលក់ចំណែកភាគហ៊ុន

(II)-ឬទុកជាចំណូលនៃទ្រព្យសម្បត្តិរដ្ឋក្នុងករណីជាប្រាក់ចំណេញតាមភាគហ៊ុន ។

ជំពូកទី ៣

ភាគកម្មសាធារណៈក្នុងមូលធនក្រុមហ៊ុនចំរុះ

មាត្រា ៣៣. មានតែរដ្ឋ គ.ស.ស ក្រ.ខ និងនីតិបុគ្គលសាធារណៈប៉ុណ្ណោះដែលមានសិទ្ធិកាន់កាប់ភាគ
កម្ម សាធារណៈ ។

អាជ្ញាធរមូលដ្ឋានក្នុងលក្ខណៈដែលពុំមាននីតិបុគ្គលភាពមិនមានសិទ្ធិកាន់ កាប់ភាគកម្ម
នៃដើមទុនក្រុមហ៊ុនណាមួយបានទេ ។

ភាគកម្មជាចំនួនភាគច្រើនដែលបាន ដាក់ក្នុងសាខា ដោយក្រុមហ៊ុនមួយដែលមានភាគ
កម្មសាធារណៈជាចំនួនភាគច្រើនមិនអនុញ្ញាតឱ្យសាខា
នេះមានលក្ខន្តិកៈជាសហគ្រាសសាធារណៈទេ ។

មាត្រា ៣៤.

៣៤.១.សកម្មភាពរបស់ ក្រ.ខ ដែលធ្វើឡើងដើម្បីសំរេចគោលដៅរបស់ក្រុមហ៊ុន ត្រូវស្ថិតនៅ
ក្រោមនីតិឯកជនលើកលែងតែមានបដិប្បញ្ញត្តិនៃច្បាប់ និងបទបញ្ជា ។

៣៤.២.ក្រុមហ៊ុនចំរុះទាំងឡាយដែល ក្នុងនោះភាគកម្មសាធារណៈស្មើឬលើសពី៥១ភាគរយ នៃដើម
ទុនរបស់ក្រុមហ៊ុន ឬសិទ្ធិបោះឆ្នោតគឺមានលក្ខណៈជាសហគ្រាសសាធារណៈ ។ ក្នុងលក្ខណៈ
នេះក្រុមហ៊ុនចំរុះ ត្រូវតែអនុវត្តបទបញ្ញត្តិទាំងឡាយដូចមានចែងនៅក្នុងជំពូកទី១ និង ជំពូក
ទី២នៃ ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ។

មាត្រា ៣៥.

៣៥.១.ភាគទុនរបស់រដ្ឋក្នុង គ.ស.ស ក្រ.ខ ឬរបស់នីតិបុគ្គលសាធារណៈក្នុងដើមទុនរបស់ ក្រ.ខ
អាចជាភាគទុនជារូបិយវត្ថុ និងជាភាគជាទុនចលនៈ និងអចលនៈទ្រព្យ ។

៣៥.២.ការបង់ចូលនូវភាគហ៊ុនជារូបិយវត្ថុ ក្នុងមូលធន ក្រ.ខ ដែលមានភាគកម្មសាធារណៈជា
ចំនួនភាគច្រើន ត្រូវបានទទួលដោយប័ណ្ណចំណូលដែលចុះហត្ថលេខាដោយ (I) អាណត្តិ
គាហកៈចាត់ តាំងដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេសចំពោះភាគទុនរបស់រដ្ឋ
(II) ម្ចាស់ភាគហ៊ុន ផ្សេងទៀតចំពោះភាគទុនរបស់ខ្លួនគេ ។ អាណត្តិគាហកៈរបស់រដ្ឋមន្ត្រី
ក្រសួងអាណាព្យាបាលបច្ចេកទេសចាត់តាំងធ្វើយ៉ាងណាឱ្យមូលនិធិសរុប ទាំងអស់ត្រូវបាន
យកទៅតំកល់ទុកក្នុងគណនីមួយនៅ រតនាគារជាតិ ឬធនាគារជាតិនៃកម្ពុជា ។ ទុនទាំងនេះ
មិនអាចប្រើមុនពេលចុះឈ្មោះក្រុមហ៊ុនក្នុង បញ្ជីពាណិជ្ជកម្មបានឡើយ ។ ការបង់ចូលនៃ
ភាគហ៊ុនជារូបិយវត្ថុក្នុងមូលធន ក្រ.ខ ដែលមានភាគកម្មសាធារណៈជាចំនួនភាគតិច

ត្រូវបានទទួលដោយប័ណ្ណចំណូលដែលចុះហត្ថលេខាដោយម្ចាស់ភាគហ៊ុនម្នាក់ៗចំពោះភាគទុនរបស់ខ្លួនគេ ។ ស្ថាបនិកដែលចាត់តាំងដោយមានការឯកភាពពីម្ចាស់ភាគហ៊ុន សំរាប់ធានាទំរង់បែបបទនៃការបង្កើតក្រ.ម ត្រូវចាត់ចែងធ្វើយ៉ាងណាឱ្យមូលនិធិសរុបទាំងអស់ត្រូវបានយកទៅតំកល់ទុកក្នុងគណនីមួយនៅរតនាគារជាតិ ឬធនាគារជាតិនៃកម្ពុជា ។ ទុនទាំងនេះ មិនអាចប្រើមុន ពេលចុះបញ្ជីក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម និងក្រុមហ៊ុនបានឡើយ ។

៣៥.៣- ភាគទុនជាទ្រព្យសម្បត្តិរបស់រដ្ឋ គ.ស.ស ក្រ.រ ឬរបស់នីតិបុគ្គលសាធារណៈត្រូវបានវាយតំលៃដោយគណៈកម្មការវាយតំលៃមួយ ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការបង់ចូលនូវភាគហ៊ុនជាចលនៈ និងអចលនៈទ្រព្យ ត្រូវមានធ្វើបញ្ជីសារពើភ័ណ្ឌដែលចុះ ហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយដែលត្រូវភ្ជាប់ជាឧបសម្ព័ន្ធជាមួយលក្ខន្តិកៈ ក្រ.ម ។

មាត្រា ៣៦.-

៣៦.១- មូលធនរបស់ក្រុមហ៊ុន ត្រូវបែងចែកជាភាគហ៊ុនដែលមានចុះឈ្មោះម្ចាស់ភាគហ៊ុនហើយត្រូវចុះបញ្ជីទាំងស្រុងនៅពេលបង្កើត ក្រ.ម ។

ភាគហ៊ុនត្រូវបានបង់ចូលក្នុងល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយលក្ខន្តិកៈរបស់ ក្រ.ម ។

៣៦.២- ភាគហ៊ុនដែលកាន់កាប់ដោយរដ្ឋ គ.ស.ស ក្រ.រ ឬនីតិបុគ្គលសាធារណៈ និងដោយម្ចាស់ភាគហ៊ុនម្នាក់ឬច្រើននាក់នៃ ក្រ.ម ត្រូវរៀបចំជាពីរប្រភេទផ្សេងគ្នាតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

ឯកសិទ្ធិរាប់បញ្ចូលទាំងឯកសិទ្ធិស្របច្បាប់ ដែលមានចែងក្នុងច្បាប់ដែល ត្រូវបានផ្តល់ឱ្យប្រភេទភាគហ៊ុនណាមួយក្នុងចំណោមប្រភេទទាំងពីរ ចាំបាច់ត្រូវមានគ្រោងទុកក្នុងអនុសញ្ញានៃ ម្ចាស់ភាគហ៊ុនដែលចុះហត្ថលេខាដោយភាគីនានានៅមុនការ បង្កើត ក្រ.ម ។

មាត្រា ៣៧.-

៣៧.១- លក្ខន្តិកៈ ក្រ.ម ដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ត្រូវបានរៀបចំឡើងដោយអនុលោមជាពិសេសតាមបទបញ្ញត្តមាត្រា ៣៤-២ ខាងលើ ដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេសដោយសហការជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។-

៣៧.២- លក្ខន្តិកៈ ក្រ.ម ដែលមានភាគកម្មសាធារណៈជាចំនួនភាគតិច ត្រូវបានរៀបចំឡើងដោយអនុលោមជាពិសេសតាមបទបញ្ញត្តមាត្រា៣៤-២ខាងលើដោយម្ចាស់ភាគហ៊ុនឯកជន

ម្នាក់ឬច្រើននាក់ដោយសហការជាមួយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋ
ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣៨.-

៣៨.១- ទំរង់នៃការបង្កើត **គ្រ.ឧ** ដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ត្រូវធ្វើ
ដោយអនុលោមទៅតាមវិធានដែលមានចែងក្នុងបទបញ្ញត្តិស្តីពីក្រុមហ៊ុនពាណិជ្ជកម្ម
អាណត្តិគាហកៈ ដែលចាត់តាំងឡើងដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស
ដែលជាអ្នក :

១- ដាក់លក្ខន្តិកៈជូនរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
ហិរញ្ញវត្ថុ ចុះហត្ថលេខារួមក្នុងនាមរដ្ឋ ។

២- ចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ហើយជារួមគឺបំពេញបែបបទចាំបាច់ ផ្សេងៗ
នីតិក្រុម ហ៊ុនពាណិជ្ជកម្ម ។

៣៨.២- ទំរង់នៃការបង្កើត **គ្រ.ឧ** ដែលមានភាគកម្មសាធារណៈជាចំនួនភាគតិច ត្រូវធ្វើ
ដោយស្ថាបនិក ដែលចាត់តាំងដោយមានការឯកភាពពីម្ចាស់ភាគហ៊ុនទាំងឡាយ អនុលោម
ទៅតាម វិធានដែលមានចែងក្នុងបទបញ្ញត្តិស្តីពីក្រុមហ៊ុនពាណិជ្ជកម្ម ។

៣៨.៣- គ្រ.ឧ អាចមាននីតិបុគ្គលចាប់ពីថ្ងៃចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ។ មុនការ
ឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុននេះមិនអាចសំរេចកិច្ចការអ្វីមួយបានទេ
លែងតែ កិច្ចការដែលសំរេចដោយអាណត្តិគាហកៈ របស់រដ្ឋមន្ត្រីក្រសួងអាណាព្យា
បច្ចេកទេស ឬដោយ ស្ថាបនិកដែលត្រូវបានចាត់តាំងដោយម្ចាស់ភាគហ៊ុនទាំងឡាយ ។

មាត្រា ៣៩.- ប្រតិបត្តិការហិរញ្ញវត្ថុទាំងឡាយដែលរដ្ឋក្នុងឋានៈជាម្ចាស់ភាគហ៊ុនអនុវត្តជាមួយ
ត្រូវអនុលោមតាមបទបញ្ញត្តិដែលចែងដោយព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃ
ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីប្រព័ន្ធច្បាប់ហិរញ្ញវត្ថុ និងលិខិតបទដ្ឋានបន្តបន្ទាប់ក្រោយៗទៀត
កិច្ច ការនេះតំរូវ :

- ភាគទុនជារូបិយវត្ថុក្នុងមូលធនចាប់ពីពេលបង្កើត **គ្រ.ឧ** ឬក្រោយពេលបង្កើតត្រូវ
គ្រោង និងអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុ ដោយចាត់ទុកជាចំណាយលើការវិនិយោគរបស់
ក្នុងកិច្ចជាប្រតិបត្តិការហិរញ្ញវត្ថុ
- ចំណូលដែលរដ្ឋបានមកពី **គ្រ.ឧ** គឺជាប្រភពចំណូលថវិកា :

(I)- ទុកជាចំណូលមូលធនក្នុងប្រទេស ក្នុងករណីមានការលក់ចំណែកភាគហ៊ុន

(II)-ឬទុកជាចំណូលនៃទ្រព្យសម្បត្តិរដ្ឋ ក្នុងករណីដែលជាប្រាក់ចំណេញតាមភាគហ៊ុន ។

ជំពូកទី ៤

អវសានបញ្ញត្តិ

មាត្រា ៤០.- បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងបទបញ្ញត្តិ ដែលមានចែងក្នុងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៤១.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាគ្រប់ក្រសួង-ស្ថាប័ន និងអភិបាលគ្រប់ខេត្ត-ក្រុង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

សូមគោរពជូន

សម្តេចនាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីតសម្បទានិងអភិវឌ្ឍន៍

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

* * *

អនុក្រឹត្យ លេខ ៤២ អនក្រ.បក

ស្តីពី ស្នងការគណនីនៃសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០១ នស/ ចុះថ្ងៃទី២៨ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការ
និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស./រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤
ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស./រកម/១២០៥/០៧ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៥
ច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៦
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦
ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស./រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦
លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៧
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១.- អនុលោមទៅតាមបទបញ្ញត្តិមាត្រា១៧នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះ ទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ អនុ នេះកំណត់លក្ខណៈវិនិច្ឆ័យនិងបែបបទនៃការតែងតាំង ការបញ្ឈប់តួនាទី និងភារកិច្ច អ្នកជំនាញការដែលទទួលបន្ទុកកិច្ចការត្រួតពិនិត្យប្រចាំឆ្នាំ នូវសហគ្រាសសាធារណៈ មានទំរង់ដូចចែងក្នុងមាត្រា៣នៃព្រះរាជក្រមខាងលើ ។ អ្នកជំនាញការនេះហៅថា **ភារគណនី** ។

ជំពូក ១

លក្ខណៈវិនិច្ឆ័យ និង បែបបទនៃការតែងតាំង ការបញ្ឈប់មុខងារ ស្នងការគណនី នៅសហគ្រាសសាធារណៈ

មាត្រា ២.- ស្នងការគណនី នៃសហគ្រាសសាធារណៈ គឺជារូបវន្តបុគ្គលឬនីតិបុគ្គលដែលមានស ខ្មែរ ឬក្រុមហ៊ុនបរទេសដែលតំណាងដោយរូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ។

ស្នងការគណនី ដែលត្រូវជ្រើសរើសនេះ ត្រូវមានសមត្ថភាពវិជ្ជាជីវៈ និងបទពិសោធន៍ការងារដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដោយរដ្ឋមន្ត្រីក្រសួង យុត្តិធម៌ ហើយបានចុះក្នុងបញ្ជីរាយនាមនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣.- **ស្នងការគណនី** ប្រចាំសហគ្រាសនីមួយៗ ត្រូវបានតែងតាំងដោយប្រកាសរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំរាប់អាណត្តិ៣ឆ្នាំ ។ អាណត្តិអាចពន្យារបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃសហគ្រាសនោះ ។

ក្នុងករណីដែលសហគ្រាសសាធារណៈទើបនឹងរៀបចំបង្កើតថ្មី ការតែងតាំង **ស្នងការគណនី** ត្រូវធ្វើឡើងក្នុងរយៈពេល១ខែបន្ទាប់ពីការប្រជុំលើកទី១ នៃក្រុមប្រឹក្សាភិបាល ។ អង្គប្រជុំលើកទីមួយនេះ ចាំបាច់ត្រូវចុះបញ្ហានេះក្នុងរបៀបវារៈរបស់ខ្លួន ។

ក្នុងករណីដែល **ស្នងការគណនី** បានតែងតាំងរួចហើយ តែស្ថិតក្នុងល័ក្ខខ័ណ្ឌណាមួយនៃមាត្រា៥ខាងក្រោមការតែងតាំង **ស្នងការគណនី** ថ្មីសំរាប់ជំនួសត្រូវធ្វើក្នុងពេលដ៏ឆាប់បំផុត ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិក្នុងការចាត់តាំង **ស្នងការគណនី** ប្រសិនបើក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិតាមកាតព្វកិច្ច ដូចបានកំណត់ខាងលើ ។

ស្នងការគណនី ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដល់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាលបើមានវិសមិតភាពណាមួយដែលមានបញ្ជាក់នៅមាត្រា៤កើតឡើង ហើយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវជូនដំណឹងបន្តទៅប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ៤.-

៤.១.- មុខងាររបស់ **ស្នងការគណនី** មានវិសមិតភាពចំពោះ :

១- មុខងាររបស់សមាជិកក្រុមប្រឹក្សាភិបាលឬប្រធានអគ្គនាយកនៃ ហគ្រាសសាធារណៈ

២- ស្វាមីភរិយា បងប្អូនបង្កើត ឪពុកម្តាយកូនចៅ របស់បុគ្គលដែលបានរៀបរាប់ក្នុង ចំណុច ១ ខាងលើ

៣-និយោជិតក្នុងសហគ្រាសដែលពាក់ព័ន្ធជាមួយការត្រួតពិនិត្យដែលបានរៀបរាប់ក្នុងចំណុច១ ខាងលើ ឬនិយោជិតរបស់ស្វាមីភរិយា បងប្អូនបង្កើត ឪពុកម្តាយកូនចៅបុគ្គលដែលបានរៀបរាប់ក្នុងចំណុច១ខាងលើ ។

៤.២.- ក្នុងដែលមានវិសមិតភាពកើតឡើង **ស្នងការគណនី** ត្រូវសុំការលាលែង ពីការងារដោយស្ម័គ្រចិត្ត តែផ្ទុយទៅវិញបើ **ស្នងការគណនី** នោះមិនបានសុំលាលែងទេ រដ្ឋមន្ត្រីក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបញ្ឈប់ការងារជាបន្ទាន់ ហើយលុបឈ្មោះចេញពីបញ្ជីរាយ នាម **ស្នងការគណនី**សំរាប់រយៈពេល២ឆ្នាំ ។

មាត្រា ៥.- **ស្នងការគណនី** នៃសហគ្រាសសាធារណៈ អាចត្រូវបញ្ឈប់ពីមុខងារក្នុងករណីដែល :

១- ចប់បេសកកម្ម : ក្នុងករណីនេះត្រូវមានការជាក់លាក់ លើកាលកំណត់នៃការិយបរិច្ឆេទ ទី៣ ដោយ ក្រុមប្រឹក្សាភិបាល ។

២- មានការសុំលាលែងដោយមានជូនដំណឹង ជាលាយលក្ខណ៍អក្សរដល់រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវជូនដំណឹងអំពីបញ្ហានេះបន្តទៅ ប្រធានក្រុមប្រឹក្សាភិបាលនៃសហគ្រាស ។ ចំពោះការសុំលាលែងដោយមានហេតុផលមិនសមស្រប ដែលចាត់ទុកថា ប៉ះពាល់ខូចប្រយោជន៍ដល់សហគ្រាស រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចសំរេចលុបឈ្មោះ **ស្នងការគណនី** ចេញពីបញ្ជីរាយនាមសំរាប់រយៈពេល ២ឆ្នាំ ។

៣- ការហូតងារ ធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមការយល់ ឃើញរបស់ខ្លួនផ្ទាល់ ឬតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។ ការហូតងារនេះនឹងធ្វើឡើង តែចំពោះករណីធ្ងន់ធ្ងរ ដែលបង្កើតឱ្យមានការមន្ទិលសង្ស័យដល់សមត្ថភាពសេចក្តីទៀងត្រង់ ភាពមិនលំអៀង ឬភាពឯករាជ្យក្នុងការងាររបស់ **ស្នងការគណនី** ។

៤- មានការពាក់ព័ន្ធដល់ចំណុចណាមួយ នៃវិសមិតភាពនៃមុខងារ ដូចបានរៀបរាប់ក្នុង មាត្រា ខាងលើ ។

៥- មានការរំលាយសហគ្រាស : ក្នុងករណីនេះ **ស្នងការគណនី** ត្រូវបំពេញមុខងាររហូតដល់ ការបញ្ចប់ប្រតិបត្តិការទូទាត់ ។

ជំពូក ២

បេសកកម្មរបស់ស្នងការគណនី

ផ្នែកទី១ : ភារកិច្ច

មាត្រា ៦.-

៦.១.-ស្នងការគណនី មានបេសកកម្ម :

១- ធ្វើការផ្ទៀងផ្ទាត់តម្លៃទឹកប្រាក់ តួលេខ និងឯកសារគណនេយ្យរបស់សហគ្រាស និងធ្វើ ត្រួតពិនិត្យលើភាពត្រូវគ្នា នៃគណនេយ្យជាមួយវិធាន និងបែបបទជាធរមាន ។

២- ធ្វើការផ្ទៀងផ្ទាត់លើភាពស្របគ្នានៃតុល្យការ និងគណនីគ្រប់គ្រង ជាមួយទិន្នន័យ គណនេយ្យ និងធ្វើការត្រួតពិនិត្យលើភាពស្មោះត្រង់នៃពត៌មានគណនេយ្យ និងហិរញ្ញវត្ថុ ដែលមានក្នុងរបាយការណ៍សកម្មភាពការងារ ។

៦.២_ស្នងការគណនី ត្រូវបញ្ជាក់ថាគណនីប្រចាំឆ្នាំមានភាពត្រឹមត្រូវ និងស្មោះត្រង់ហើយ ត្រូវបង្ហាញទិដ្ឋភាពពិតប្រាកដ ស្តីពីសភាពការណ៍ហិរញ្ញវត្ថុ និងស្តីពីទ្រព្យសម្បត្តិរបស់សហគ្រាស ។ ផ្អែកតាមគោលការណ៍នេះ **ស្នងការគណនី** អាច :

១- បដិសេធមិនធ្វើការបញ្ជាក់លើគណនី

២- ធ្វើការបញ្ជាក់ជាបណ្តោះអាសន្នលើគណនី

៣- បញ្ជាក់លើគណនីដោយយល់ស្របទាំងស្រុង

៦.៣_ ស្នងការគណនី មិនមានសិទ្ធិបំពេញអត្ថបទច្បាប់គ្រប់ប្រភេទបានទេ ។ ហើយមិនអាចធ្វើកិច្ចការច្បាប់ដែលព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ខែសីហា ឆ្នាំ១៩៩៥ កំណត់ថា ជាកិច្ចការរបស់មេធាវី ។

មាត្រា ៧_

៧.១_ស្នងការគណនី រៀបចំធ្វើរបាយការណ៍រួម និងរបាយការណ៍ពិសេស ដែលមានចំណុចសំខាន់ៗដូចតទៅ :

១-ពត៌មានអំពីការត្រួតពិនិត្យ និងកាផ្ទៀងផ្ទាត់ ដែលបានធ្វើក្នុងក្របខ័ណ្ឌបេសកកម្មកំណត់ក្នុងមាត្រា៦ ខាងលើ

២- លើកឡើងពីការប្រែប្រួលគណនី និងវិធីសាស្ត្រវាយតម្លៃ

៣- កត់សំគាល់អំពីភាពមិនប្រក្រតីនិងភាពមិនត្រឹមត្រូវដែលបានសង្កេតឃើញ

៤- លើកសំណើសុំធ្វើការកែសំរួល ដែលអាចមានប្រយោជន៍ដល់ឯកសារនិងវិធីសាស្ត្រគណនេយ្យ

៥- លើកយោបល់លើភាពស្របគ្នារវាងទិន្នន័យគណនេយ្យ ជាមួយរបាយការណ៍ សកម្មភាពការងារ និងគណនីប្រចាំឆ្នាំ ។ លើកយោបល់អំពីគណនីប្រចាំឆ្នាំ ។ ក្នុងករណីនៃការបដិសេធពុំព្រមធ្វើការបញ្ជាក់ លើគណនីត្រូវលើកឡើងនូវមូលហេតុ ដែលឈានដល់ការបដិសេធនេះ ។ ក្នុងករណីព្រមបញ្ជាក់លើគណនីក្នុងសភាពបណ្តោះអាសន្ន ត្រូវបញ្ជាក់នូវមូលហេតុដែលឈានដល់ភាពបណ្តោះអាសន្នទាំងនោះ ។

៧.២- **ស្នងការគណនី** ត្រូវបញ្ជូនរបាយការណ៍ទាំងនេះ (ទាំងរបាយការណ៍ដែលមានចែងក្នុងមាត្រា៨ខាងក្រោមនេះ) ទៅប្រធានក្រុមប្រឹក្សាភិបាល រដ្ឋមន្ត្រីក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស និងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាល អាចប្រកាសបិទបញ្ជីគណនីជាស្ថាពរ លុះត្រាណាមានរបាយការណ៍របស់ **ស្នងការគណនី** មកជាមួយ ។

ការអាក់ខានមិនបានធ្វើរបាយការណ៍របស់ **ស្នងការគណនី** ក្នុងរយៈពេលកំណត់ ត្រូវចាត់ទុកជាកំហុស ដែលអាចនាំមកនូវការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ។

មាត្រា ៨.-

៨.១- ប្រសិនបើ **ស្នងការគណនី** ស្រង់ឃើញក្នុងការិយបរិច្ឆេទនៃរយៈពេលបេសកកម្មខ្លួននូវសកម្មភាពដែលជាហេតុនាំឱ្យខូចដល់និរន្តរភាពនៃដំណើរការសហគ្រាសឬសកម្មភាពល្មើសនឹងច្បាប់ឬបទបញ្ញារបស់សហគ្រាស **ស្នងការគណនី** ត្រូវជូនដំណឹងតាមរបាយការណ៍ពិសេសយ៉ាងឆាប់បំផុត ទៅប្រធានក្រុមប្រឹក្សាភិបាល រដ្ឋមន្ត្រីក្រសួងអាណាព្យាបាល ឬអាជ្ញាធរ អាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៨.២- ប្រសិនបើ **ស្នងការគណនី** ស្រង់ឃើញក្នុងការិយបរិច្ឆេទ នៃរយៈពេលបេសកកម្មខ្លួននូវហេតុការណ៍ឬអំពើដែលផ្ទុយនឹងច្បាប់ឬបទបញ្ញាទាំងឡាយរបស់សហគ្រាស **ស្នងការគណនី** ត្រូវជូនដំណឹងតាមរបាយការណ៍ពិសេសយ៉ាងឆាប់បំផុតទៅអាជ្ញាធរដូចមានចែងក្នុងមាត្រា ៨-១ ខាងលើ ។

៨.៣- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបញ្ឈប់ការងារជាបន្ទាន់ ហើយលុបឈ្មោះចេញពីបញ្ជីរាយនាម **ស្នងការគណនី** សំរាប់រយៈពេល ៣ឆ្នាំ ចំពោះ **ស្នងការគណនី** ដែលមិនគោរពនូវកាតព្វកិច្ច ដែលមានចែងក្នុងមាត្រា៨-១ និង ៨-២ ខាងលើ ។

មាត្រា ៩.- **ស្នងការគណនី** ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈសំរាប់គ្រប់សកម្មភាព ឬព្រឹត្តិការណ៍ទាំងឡាយដែលខ្លួនបានដឹងឮ ក្នុងរយៈពេលបំពេញបេសកកម្ម និងក្រោយពេលបំពេញបេសកកម្ម ។ **ស្នងការគណនី** ត្រូវទទួលទោសរដ្ឋប្បវេណីតាមច្បាប់ជាធរមានក្នុងករណី **ស្នងការគណនី** ធ្វើឱ្យធ្លាយការសម្ងាត់ ។

ជំពូកទី២ ៖ សិទ្ធិ

មាត្រា ១០.-

១០.១.- សហគ្រាសសាធារណៈត្រូវផ្តល់ជូន **ស្នងការគណនី** គ្រប់ពេលវេលាទាំងអស់ នូវឯកសារ របាយការណ៍ កិច្ចសន្យា សៀវភៅកំណត់ហេតុ លិខិតស្នាមគណនីនិងលិខិតបញ្ជាក់ទាំងអស់ ដែលចាំបាច់ក្នុងការអនុវត្តន៍បេសកកម្មរបស់ **ស្នងការគណនី** ។

១០.២.-ស្នងការគណនី អាចចាត់ចែងធ្វើការស៊ើបអង្កេត ឬការត្រួតពិនិត្យដែលខ្លួនយល់ថាចាំបាច់នៅគ្រប់កាលៈទេសៈ ។

១០.៣.-ស្នងការគណនី អាចអញ្ជើញឱ្យមកជាជំនួយការ ក្រោមការទទួលខុសត្រូវរបស់ខ្លួននូវអ្នកជំនាញការ ឬសហការីដែលខ្លួនបានជ្រើសរើសផ្ទាល់ និងចាត់តាំងសំរាប់សហគ្រាសហើយ ដែលមានសិទ្ធិដូចគ្នាក្នុងការទំនាក់ទំនងការងារ និងការស៊ើបអង្កេត ។

១០.៤.-ស្នងការគណនី អាចទទួលគ្រប់ពត៌មានចាំបាច់ទាំងអស់ សំរាប់បេសកកម្មរបស់ខ្លួនពីតតិយជន ដែលធ្វើប្រតិបត្តិការជាគុណប្រយោជន៍ដល់សហគ្រាស ។

មាត្រា **១១.-ស្នងការគណនី** ត្រូវបានអញ្ជើញដោយប្រធានក្រុមប្រឹក្សាភិបាល ឱ្យចូលរួមក្នុងការប្រជុំស្តីអំពីការបិទគណនីប្រចាំឆ្នាំ ឬក្នុងការប្រជុំផ្សេងទៀតដែលចាត់ទុកជាការចាំបាច់ ។

ជំពូកទី ៣ ៖ ការទទួលខុសត្រូវ

មាត្រា ១២.-

១២.១.-ស្នងការគណនី ត្រូវទទួលខុសត្រូវទាំងចំពោះមុខសហគ្រាស ទាំងចំពោះមុខតតិយជន លើការខូចខាតបណ្តាលពីកំហុស ឬការធ្វេសប្រហែសរបស់ខ្លួន ដែលបានធ្វើក្នុងពេលអនុវត្តបេសកកម្ម ។

១២.២.-ស្នងការគណនី ទទួលខុសត្រូវបទព្រហ្មទណ្ឌ ក្នុងករណីដែលផ្តល់ឬការអះអាងពត៌មានដែលខ្លួនដឹងថាជាពត៌មានក្លែងក្លាយ និង លុបឈ្មោះចេញពីបញ្ជីរាយនាម **ស្នងការគណនី** ។

ជំពូកទី ៤ ៖ លាភការ

មាត្រា ១៣.-

១៣.១.- លាភការរបស់ **ស្នងការគណនី** ត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល ទៅតាមទំហំការងារចាំបាច់សំរាប់ការអនុវត្តន៍បេសកកម្មដែលបានកំណត់ក្នុងមាត្រា៦ និង៧ ខាងលើ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស./រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស./រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/ប្រក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១.- ត្រូវបានបង្កើត អង្គភាពសំរបសំរួលការងារនីតិកម្មមួយ នៅទីស្តីការគណៈរដ្ឋមន្ត្រីដែលស្ថិតនៅក្រោមឱវាទរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២.- អង្គភាពសំរបសំរួលការងារនីតិកម្ម ត្រូវបំពេញភារកិច្ចដូចតទៅ :

១- សិក្សាវិភាគ លើប្រព័ន្ធគតិយុត្តសព្វថ្ងៃក្នុងគោលបំណង :

(ក) -កំណត់ឱ្យដឹងអំពីរាល់សកម្មភាពជាអាទិភាព ដើម្បីតាក់តែងនូវ អត្ថបទនី ត្យានុកូលឡើងវិញ ។

(ខ) - លើកគំរោងផែនការសកម្មភាពរយៈពេលមធ្យម ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃការងារកែទំរង់ ។

(គ) - ធ្វើការវាយតម្លៃអំពីតម្រូវការការបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកគតិយុត្ត ដែលចាំបាច់និងកំណត់នូវសកម្មភាពជាអាទិភាពដើម្បីធ្វើឱ្យសំរេចនូវតំរូវការខាងលើនេះ ។

២- ជួយកំណត់នូវ គោលការណ៍ដឹកនាំ នៃប្រព័ន្ធគតិយុត្ត ថ្មីមួយដែល :

(ក) - ស្របទៅនឹងបទបញ្ញត្តិរបស់រដ្ឋធម្មនុញ្ញ ។

(ខ) - ស្របតាមទិសដៅរបស់រាជរដ្ឋាភិបាល ។

(គ) - រក្សានូវភាពរលូនគ្នា ។

(ឃ) - ជំរុញឱ្យមាន អភិវឌ្ឍនកម្មស៊ីចង្វាក់នឹងសេដ្ឋកិច្ចទីផ្សារ ។

(ង) - ងាយយល់ដល់អ្នកដែលទទួលបន្ទុកអនុវត្ត និងដល់ប្រជាជន ។

៣- រួមចំណែកជួយក្រសួង រដ្ឋលេខាធិការដ្ឋាន ឬអង្គភាពសាធារណៈក្នុងការតាក់តែង សេ... ព្រាងច្បាប់ លិខិតបទដ្ឋាន នីតិបញ្ញត្តិ ឬបទបញ្ញត្តិគតិយុត្ត ។

៤- គ្រប់គ្រងមូលដ្ឋានទិន្នន័យគតិយុត្ត ។

៥- ជួយដល់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ននានា ក្នុងការពង្រឹងសមត្ថភាព លើវិស័... គតិយុត្ត ។

៦- ផ្តល់ការទ្រទ្រង់លើវិស័យគតិយុត្ត ដល់គ្រប់ក្រសួងស្ថាប័ន ដែលស្នើសុំ (ផ្តល់ពត៌មាន-ផ្ត... មតិបកស្រាយ-វិភាគផ្នែកគតិយុត្តលើឯកសារឬកិច្ចសន្យា ។ល។)

៧- វាយតំលៃ និង ជួយសំរបសំរួលរាល់កម្មវិធីគតិយុត្ត ដែលទទួលហិរញ្ញប្បទានពីអ្នកផ្ត... ជំនួយពហុភាគី ឬទ្វេភាគី ។

៨- ធ្វើការសិក្សា ដឹកនាំ ឬចូលរួមក្នុងគ្រប់សកម្មភាពសំរបសំរួល លើវិស័យកែទំរង់... ប្រព័ន្ធគតិយុត្ត តាមការស្នើសុំរបស់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

៩- ផ្តល់ជំនួយបច្ចេកទេស ដល់ក្រុមប្រឹក្សាអ្នកច្បាប់ និងអគ្គលេខាធិការរាជរដ្ឋាភិបាល ។

មាត្រា ៣.- អង្គភាពសំរបសំរួលការងារនីតិកម្ម ត្រូវបានដឹកនាំដោយនាយកមួយរូប ដែលត្រូវតែងតាំ... ដោយអនុក្រឹត្យ តាមសំណើរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ បេក្ខជ... ត្រូវមានសញ្ញាប័ត្រនីតិសាស្ត្រ ចាប់ពីថ្នាក់ឧត្តមឡើងទៅ និងត្រូវមានបទពិសោធន៍គ្រ... គ្រាន់សំរាប់បំពេញមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។ នាយកដឹកនាំរាល់ការងាររបស់... អង្គភាព និងជាអាណាប័កប្រតិភូនៃថវិការបស់អង្គភាពសំរបសំរួលការងារនីតិកម្ម ដែ... ជាថវិកាឧបសម្ព័ន្ធរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ នាយកមានសិទ្ធិអំណាចជ្រើសរើសក្រុមជ... បុគ្គលិកចុះហត្ថលេខាលើកិច្ចសន្យា ហើយជាទូទៅមានអំណាចចាំបាច់សំរាប់ការគ្រប់គ្រ... ជាប្រចាំនៃអង្គភាព ។

នាយកអង្គភាពត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ស្តីពីសកម្មភាពរបស់អង្គភាពជូនទៅ... សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៤.- រចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅ របស់អង្គភាពសំរបសំរួលការងារនីតិកម្ម នឹងត្រូវកំណ... ដោយប្រកាសរបស់ សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៥.- មុខតំណែងនៃបុគ្គលិកអចិន្ត្រៃយ៍របស់អង្គភាព នឹងត្រូវបានបំពេញដោយមន្ត្រីរាជការស៊ីវិ... ដែលត្រូវបានចាត់តាំងឬផ្ទេរចេញឱ្យមកបំរើការងារនៅក្នុងអង្គភាព ។ បេក្ខជនត្រូវ...

ជំនាញសមត្ថភាពនិងបទពិសោធន៍គ្រប់គ្រាន់ស្របទៅនឹងមុខងាររបស់ខ្លួន ។ នៅក្នុងករណីចាំបាច់មុខតំណែងទាំងនោះ អាចបំពេញដោយបុគ្គលិកជាប់កិច្ចសន្យា ប្រសិនបើមានហិរញ្ញប្បទានពីអ្នកផ្តល់ជំនួយសំរាប់ជំពូកនេះ ។ បុគ្គលិកជាប់កិច្ចសន្យាទាំងនោះ ត្រូវមានជំនាញសមត្ថភាពនិងបទពិ សោធន៍គ្រប់គ្រាន់ស្របទៅនឹងមុខងាររបស់ខ្លួន ។

បុគ្គលិកអចិន្ត្រៃយ៍ របស់អង្គភាពនឹងអាចទទួលបាននូវប្រាក់ឧបត្ថម្ភ ទៅតាមកំរិតនៃសកម្មភាពរបស់អង្គភាព ហើយដែលចំនួនទឹកប្រាក់និងរបៀបបែងចែក និងត្រូវកំណត់ដោយនាយក និង ដោយមានការយល់ព្រមផង ពីសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ ប្រាក់ ឧបត្ថម្ភទាំងនេះ ត្រូវបានយកចេញពីថវិការបស់អង្គភាព ។

មាត្រា ៦.- នាយកមានសិទ្ធិជ្រើសតាំង អ្នកជំនាញការសំរាប់រយៈពេលមានកំណត់ ដើម្បីបំពេញការងារពេញពេលឬពាក់កណ្តាលពេល ដោយមានការយល់ព្រមពី សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី ។

មាត្រា ៧.- ហិរញ្ញប្បទាននៃសកម្មភាពរបស់អង្គភាព ត្រូវបានធានាដោយ :

- ប្រាក់អំណោយពិសេស របស់រាជរដ្ឋាភិបាលនៅក្នុងក្របខ័ណ្ឌនៃថវិការបស់អង្គភាព ។
- ជំនួយជាឥណទាន ជាអំណោយ ផ្តល់ដោយអ្នកផ្តល់អំណោយពហុភាគី ឬទ្វេភាគី ។

មាត្រា ៨.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និង អង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

អនុក្រឹត្យ លេខ ១២១ អនក្រ.តត

ស្តីពីការកែតំរូវក្រុមប្រឹក្សាភិបាល នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.- តែងតាំងអស់លោក ដែលមានឈ្មោះខាងក្រោម ជាក្រុមប្រឹក្សាភិបាលអាណត្តិទី ១ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ៖

១- ឯកឧត្តម **ឈឹម សៀកឡេង** ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ តំណាងសាលាក្រុងភ្នំពេញ ជាប្រធាន

២- លោក **ខៅខ មុំនឿន** អនុប្រធានទី១ នាយកដ្ឋានរដ្ឋបាលទូទៅ តំណាងក្រសួងមហាផ្ទៃ ជាសមាជិក

៣- លោក **គីខ គៅរទ្ធី** ប្រធាននាយកដ្ឋានជលសាស្ត្រ និង ទំនប់ធំៗនៃក្រសួងសាធារណការ និងដឹកជញ្ជូន តំណាង ក្រសួងសាធារណការនិងដឹកជញ្ជូន ជាសមាជិក

៤- លោក **គាំខ សោខខំណា** អនុប្រធាន នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៥- លោក **កែខ ទារ៉ាត** អនុប្រធាន នាយកដ្ឋានផែនការ និងជាប្រធានអង្គភាពទឹកស្អាត នៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពលតំណាងក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ជាសមាជិក

៦- លោក **ឯក ស៊ុនចាន់** អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញជាសមាជិក

៧- លោក **សែម ម៉ិនមោខ** តំណាងនិយោជិត រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ជាសមាជិក

មាត្រា ២.-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងអស់លោកដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ១២២ អនក្រ.តត

ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហានជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និងនាយក រដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សម្រេច

មាត្រា ១.- ត្រូវបានតម្លើងឋានន្តរស័ក្តិជា **ឧត្តមសេនីយ៍ឯក** ជូន :

- លោក វរសេនីយទោ **ម៉ាំន សុផល** អត្តលេខ ០០០៩៧២ ជាមេបញ្ជាការរងកងឧទ្ទម្ភាគចក្រ

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះដែលចូលជាធរមានច្បាប់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ១២៣ អនក្រ.តត

ស្តីពីការជូនមេដាយ សហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋា ភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឈឹម ឌិមយ៉ុន**

សំរេច

មាត្រា ១.- ត្រូវបានប្រគល់មេដាយ ធិបឌិន្ទ សហមេត្រី ជូនលោកវរសេនីយ៍ឯក Jean-Yves BLOUIN នាយកវរងបេសកកម្មសហប្រតិបត្តិការយោធាបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានជួយជ្រោមជ្រែងអស់ពីកម្លាំងកាយចិត្ត សំភារៈនិងបច្ចេកទេស ក្នុងការអភិវឌ្ឍន៍ កងយោធពលខេមរភូមិន្ទឱ្យមានលក្ខណៈទំនើប ទាន់សម័យ ព្រមទាំងលើកស្ទួយចំណងមិត្តភាព និងសហប្រតិបត្តិការបារាំង-ខ្មែរ ទទួលបានលទ្ធផលល្អប្រសើរ ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងឯកឧត្តម ឧត្តមសេនីយ៍ឯក **ឃឹម ខិមយ៉ុន** ត្រូវអនុវត្តអនុក្រឹត្យ នេះឱ្យទទួលបានលទ្ធផលល្អ ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមី ខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១៥៣ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ ០២ ន.ស . ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ.១៩៩៤
- ពិនិត្យសំណូមពរការងារ និងសមត្ថភាពរបស់មន្ត្រីរាជការ

សម្រេច

មាត្រា ១.- ត្រូវបានតែងតាំងលោក **អ៊ិត សារឿន** ជាជំនួយការ ឯកឧត្តម ឧត្តមសេនីយ៍ទោ ហោង បូរិន្ទ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** និងមានឋានន្តរសក្តិជា**វរសេនីយ៍ឯក** នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារប្រទេស រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១៥៤ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយ

ព្រះរាជក្រម លេខ ០២ ន.ស . ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

- ពិនិត្យសំណូមពរការងារ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា ១.- ត្រូវបានតែងតាំងជាជំនួយការឯកឧត្តមឧត្តមសេនីយ៍ឯក **គង់ គីម** របស់សកជនសេស សម្តេចនាយករដ្ឋមន្ត្រីទី ២ដូចមានរាយនាមខាងក្រោម :

១- លោក **មួន សារិន** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

២- លោក **តេង ជន់** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៣- លោក **ងាស សឿន** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៤- លោក **ជួន សុវណ្ណ** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៥- លោក **ឈឿ ស៊ីដារ៉ា** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៦- លោក **គង់ សំបូរ** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៧- លោក **ហែម ធន** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៨- លោក **ញ៉ី ជុំវីណា** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**

៩- លោក **សុខ ចារុវណ្ណ** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១៥៥ អនក្រ.ត.ត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ០២ ន.ស./៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- ពិនិត្យសំណូមពរការងារ និងសមត្ថភាពរបស់មន្ត្រីរាជការ

សម្រេច

មាត្រា ១.- ត្រូវបានតែងតាំងជាសមាជិកក្រុមលេខា សម្តេចសម្តេចនាយករដ្ឋមន្ត្រីទី២ ដូចមានរាយនាមខាងក្រោម:

១- លោក **ម៉ាញ សំអាត** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើ មុខងារ បច្ចុប្បន្ន

២- លោក **សេង ឡេង** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៣- លោក **ចៅ តុល** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១៥៦ អនក្រ.តត
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស /រកត/១០៩៤/៩០ ចុះថ្ងៃ ទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ ០២ ន.ស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងសំណើរបស់ក្រសួងពត៌មាន

សំរេច

មាត្រា ១.- ត្រូវបានតែងតាំងលោក **សាន ម៉ុនរិទ្ធ** ជាប្រធាននាយកដ្ឋានសំភារៈបរិក្ខារនៃក្រសួងពត៌មាន ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១៥៧ អនក្រ.តត
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយ ព្រះរាជក្រម លេខ ០២ ន.ស ./ ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងសំណើរបស់ក្រសួងពត៌មាន

សំរេច

ប្រការ ១.- ត្រូវបានតែងតាំងលោក **អឿង ឧត្តរ** ជាប្រធាននាយកដ្ឋានផែនការគណនេយ្យនិង ហិរញ្ញវត្ថុ នៃក្រសួងពត៌មាន ។

ប្រការ ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ព្រមទាំងសាមីខ្លួន ត្រូវ ទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះ ហត្ថលេ ខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១៥៨ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រម លេខ ០២ ន.ស/ ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងសំណើរបស់រដ្ឋមន្ត្រីក្រសួងការពត៌មាន

សម្រេច

មាត្រា ១.- ត្រូវបានតែងតាំងជា **អគ្គនាយករង** ទូរទស្សន៍ជាតិកម្ពុជា នៃក្រសួងព័ត៌មាន ដូចមានរាយនាមខាងក្រោម :

១- លោក **ហ៊ឹម សួង**

២- លោក **គីម គុណនទ្ឋុន**

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងដែលពាក់ព័ន្ធនិង សាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១៤៩ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤
- ពិនិត្យសំណូមពរការងារ និងសមត្ថភាពរបស់មន្ត្រីរាជការ

សម្រេច

មាត្រា ១.- ត្រូវបានតែងតាំងលោក **ឃាម ឋាតិ** ជាជំនួយការលោកជំទាវ ហូ ណុន ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

ប្រការ ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១៦០ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- ពិនិត្យសំណូមពរការងារ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

ប្រការ ១.- ត្រូវបានតែងតាំងជាជំនួយការ ឯកឧត្តម ឧត្តមសេនីយ៍ឯក **គន់ គីម** បេសកជន ពិសេសសម្តេច នាយករដ្ឋមន្ត្រីទី២ ចំនួន ០៧ រូប ដូចមានរាយនាមខាងក្រោម :

១- លោក **សុខ យាន** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

២- លោក **អ៊ុច សារិទ្ធ** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៣- លោក **ឡៅ សារុន** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៤- លោក **សោម ជិន** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៥- លោក **សុខ សុវណ្ណ** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៦- លោក **នួន ឧសារិន** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៧- លោក **គង់ វណ្ណា** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

អនុក្រឹត្យលេខ ១៦១ អនក្រ.តត
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ ន.ស/ ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស /រកត./១០៩៤./៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស /រកត./១០៩៤./៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី១៥ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតនិងភាពសំរបសំរួលការងារនីតិកម្មនៅទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើររបស់ សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១.- តែងតាំងឯកឧត្តម **ឃោង ចន្ទ្រម៉ុនរាត** ជានាយកនៃអង្គភាពសំរបសំរួលការងារនីតិកម្ម នៅទីស្ដីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ សីហា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

២- សេចក្ដីសំរេច

រាជធានីភ្នំពេញ .ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧

សេចក្ដីសំរេចលេខ ២៧ សសរ ស្ដីពី ការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងកិច្ចការនារី

សំរេច

ផ្ទេរសិទ្ធិជូនឯកឧត្តម **ស៊ុំ ម៉ានិត** រដ្ឋលេខាធិការនៃទីស្ដីការគណៈរដ្ឋមន្ត្រី ជារដ្ឋលេខាធិការស្ដីទី នៃក្រសួងកិច្ចការនារីជំនួសឯកឧត្តម **គៀត សុគន្ធ** ដែលត្រូវអញ្ជើញទៅបំពេញ

បេសកកម្មនៅបរទេសចាប់ពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៧ រហូតដល់ឯកឧត្តមវិលត្រឡប់មកក្នុងប្រទេសវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម **ស៊ុំ ម៉ារិត** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ២៨ សសរ

ស្តីពី ការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការតែងតាំង ឯកឧត្តម **អ៊ឹង ហួត** ជានាយករដ្ឋមន្ត្រីទី១ ជំនួសសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ
- តាមសំណូមពរចាំបាច់

សម្រេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី និងផ្ទេរសិទ្ធិជូនឯកឧត្តម **យូ ហុកគ្រី** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជារដ្ឋមន្ត្រីស្តីទី ចាប់ពីថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧ រហូតដល់ពេល នាយករដ្ឋមន្ត្រីទាំងពីរវិលត្រឡប់មកក្នុងប្រទេសវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃគ្រប់ក្រសួង ស្ថាប័ន ឯកឧត្តម **ស ខេង** និងឯកឧត្តម **យូ ហុកគ្រី** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

III - ការងារបណ្តាក្រសួង

១- ទីស្តីការគណៈរដ្ឋមន្ត្រី

៣- ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាស លេខ ៦៥ ប្រក/មស

ស្តីពីការ តែងតាំងមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

...បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤
- យោងតាមការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

ប្រការ ១ : តែងតាំងលោក **ម៉ុន សេ** ជាអនុប្រធាននាយកដ្ឋានកុំព្យូទ័រ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ២ : ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សុខ អាន

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាស លេខ ៦៦ ប្រក/មស

ស្តីពីការ តែងតាំងមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤
- យោងតាមការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

ប្រការ ១ : តែងតាំងលោកស្រី **នាន់ ស៊ីណន់** ជាអនុប្រធាននាយកដ្ឋានគមនាគមន៍ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ២ : ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សុខ អាន

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាស លេខ ៦៧ ប្រក/មល

ស្តីពីការ តែងតាំងមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤
- យោងតាមការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

ប្រការ ១ : តែងតាំងលោក **សៀម ទារ៉ន់** ជាអនុប្រធាននាយកដ្ឋានកុំព្យូទ័រ នៃទីស្តីការគណៈរដ្ឋមន្ត្រី

ប្រការ ២ : ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា

សុខ អាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាស លេខ ៦៨ ប្រក

ស្តីពីការ តែងតាំងមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤
- យោងតាមការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : តែងតាំងលោកស្រី **សែម នាង** ជាអនុប្រធាននាយកដ្ឋានតំកល់ឯកសារនៃ ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ២ : ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សុខ អាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាស លេខ ៦៩ ប្រក

ស្តីពីការ តែងតាំងមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤
- យោងតាមការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : តែងតាំងលោក **ទឹម សុនមារ៉ានី** ជាអនុប្រធាននាយកដ្ឋាន ពាណិជ្ជកម្ម-ហិរញ្ញវត្ថុ និងធនាគារ នៃ ទីស្តីការ គណៈរដ្ឋមន្ត្រី ។

ប្រការ ២ : ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សុខ អាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាស លេខ ៧០ ប្រក

ស្តីពីការ តែងតាំងមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤
- យោងតាមការចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : តែងតាំងលោក **យុន ខោច** ជាប្រធានការិយាល័យសហប្រតិបត្តិការ នៃនាយកដ្ឋានផែនការ-សហប្រតិបត្តិការ ទីស្តីការ គណៈរដ្ឋមន្ត្រី ។

=

ប្រការ ២ : ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច នាយកដ្ឋានផែនការ-សហប្រតិបត្តិការ ព្រមទាំង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សុខ អាន

* * *

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាស លេខ ២២៣ ពណ.ចល.ប្រក

ស្តីពីការ បង្កើតការិយាល័យ អាស៊ាន

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ របស់ព្រះបាទនរោត្តម **សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បង្កើតក្រសួងពាណិជ្ជកម្ម ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ៩/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

រចាំបាច់របស់ក្រសួង

សម្រេច

: បង្កើតការិយាល័យអាស៊ាន ចំណុះនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស នៃក្រសួងពាណិជ្ជកម្ម ។

ប្រការ ២ : ភារកិច្ចរបស់ការិយាល័យអាស៊ានមាន :

-សិក្សាស្រាវជ្រាវនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជា និងរបស់បណ្តាប្រទេសជាសមាជិកអាស៊ាន ។

- សិក្សាពីការរួមបញ្ចូលនៃសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ ។

- ទំនាក់ទំនងជាមួយបណ្តាប្រទេស ជាសមាជិកអាស៊ាន ។

- ត្រៀមរៀបចំមុខទំនិញសំរាប់បញ្ចូលក្នុងកម្មវិធីអនុគ្រោះពន្ធគយដែលអនុវត្តជារួម (CEPT Scheme) ដើម្បីអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ។

ប្រការ ៣ : ការិយាល័យអាស៊ានដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជំនួយការ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ត្រូវអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាស លេខ ២២៤ ពណ.គន.ប្រក

ស្តីពីការ ប្រគល់ទីតាំងស្ថានីយ៍ប្រេង "អេសសូ"

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញកិច្ចសន្យាជួលទីតាំង ស្ថានីយ៍ប្រេង "អេសសូ" នៅក្រុងព្រះសីហនុ របស់ក្រុមហ៊ុនសំភារៈបរិក្ខារ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៧ រវាងក្រុមហ៊ុនសំភារៈបរិក្ខានៃក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុនមុន្នីស៊ីណាម៉ិច

សំរេច

ប្រការ ១ : ប្រគល់ការគ្រប់គ្រងទីតាំងស្ថានីយ៍ប្រេង "អេសសូ" របស់ក្រុមហ៊ុនសំភារៈបរិក្ខារ ដូចមានចែងក្នុងប្រការ១ នៃកិច្ចសន្យាជូលក្រុមហ៊ុន មុន្នីណាម៉ិច ។

ប្រការ ២ : ក្រុមហ៊ុនមុន្នីស៊ីណាម៉ិច ត្រូវគោរព និង អនុវត្តឱ្យបានល្អតាមរាល់ប្រការ ដែលមានចែងក្នុងកិច្ចសន្យា ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៧ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានក្រុមហ៊ុនសំភារៈបរិក្ខារ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យទទួលបានលទ្ធផលល្អប្រសើរ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

* * *

៣. នីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

ប្រកាស

រាជធានីភ្នំពេញថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាសប្រកាសលេខ ៣៣៤ ប្រក

ស្តីពី

ការប្រគល់សិទ្ធិចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- ... រាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ របស់ព្រះបាទសម្តេចព្រះ ...ន្ត សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៤/៥០ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ តែងតាំង ឯកឧត្តម ឯម សំអាន ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨៩៤/៥៨ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៥ តែងតាំង ឯកឧត្តម កឿង វ៉ាង ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ

- បានឃើញច្បាប់ស្តីពីរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- ដើម្បីដឹកនាំ គ្រប់គ្រង ក្រសួងមហាផ្ទៃឱ្យមានប្រសិទ្ធភាព និងមានការកំណត់ភារកិច្ចទទួល ខុសត្រូវ ច្បាស់លាស់

សំរេច

ប្រការ ១ : ត្រូវបានប្រគល់ភារកិច្ចជូន ឯកឧត្តម **គៀង វ៉ាង** បច្ចុប្បន្នសហរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកផ្នែក រដ្ឋបាលស៊ីវិល ឱ្យទទួលបន្ថែមជា សហរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលផ្នែកនគរបាលជាតិ ដោយអនុវត្តតាមលក្ខណៈការណ៍សហព័ទ្ធសំរេចជាមួយ ឯកឧត្តម **ឯម សំអាន** សហរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ។

ប្រការ ២ : ឯកឧត្តម **គៀង វ៉ាង** ត្រូវទទួលបន្ទុកបំពេញការងារទាំងពីរផ្នែក (រដ្ឋបាលស៊ីវិល និងនគរបាលជាតិ) ចាប់ពីពេលនេះរហូតដល់មានការតែងតាំងសហរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃថ្មី សំរាប់ទទួលបន្ទុក កិច្ចការរដ្ឋបាលស៊ីវិល ។

ប្រការ ៣ : នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋាននគរបាល អគ្គធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ឯកឧត្តមដែលមានឈ្មោះ ក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា និង ត្រា

ស ខេង **យូ ហុកគ្រី**

* * *

៤. និស្ត័ភារដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃ ទី ០៤ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២១១/៩៧ ព.ម.ប្រក

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- ពិនិត្យសំណើសុំអនុញ្ញាតតំឡើងផ្កាយរណប JCSAT នៅក្នុងព្រះរាជាណាចក្រកម្ពុជា របស់លោក SHINICHI HARADA តំណាង NHK ចុះថ្ងៃទី ១៧ /៧ /៩៧

សម្រេច .

ប្រការ ១ : អនុញ្ញាតជូនលោក SHINICHI HARADA និងលោក KAZUMASA OKAJIMA តំណាង NHK (Japan Broadcasting Corporation) ដែលមានទីតាំងស្ថិតនៅ 2-2-1 JINNAN SHIBUYA TOKYO 150-01 JAPAN តំឡើងផ្កាយរណប JCSAT ប្រព័ន្ធ DIGITAL CSP (NHK'S Flyway) ធ្វើការផ្សាយរយៈពេលបណ្តោះអាសន្នពីព្រះរាជាណា ចក្រកម្ពុជា ។

ប្រការ ២ : សាមីខ្លួនត្រូវអនុវត្តតាមគោលការណ៍ច្បាប់កំណត់ និង ច្បាប់ពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា ហើយហាមប្រើប្រាស់ប្រព័ន្ធនេះដើម្បីធ្វើនយោបាយ ឬពាណិជ្ជកម្មដែលផ្ទុយពីច្បាប់រដ្ឋ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ២ សាមីខ្លួន ត្រូវទទួលទោសតាមច្បាប់ជាធរមាន

ប្រការ ៤ : អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា -នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ -សោតទស្សន៍នៃអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុក្រសួងព័ត៌មាន មន្ទីរព័ត៌មានរាជធានីភ្នំពេញ អាជ្ញាធរដែល មានការពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀង១ ខ្លួន។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៧ រហូតដល់ពេលដែលសំភារៈទាំងនេះនឹងត្រូវនាំចេញពីព្រះរាជាណាចក្រកម្ពុជា ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ ថ្ងៃ ទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២១២/៩៧ ព.ម.ប្រក

ស្តីពី

ការអនុញ្ញាតឱ្យបើកអាជីវកម្មរោងពុម្ព "ខែមការ៉ូ"

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ច្បាប់ស្តីពីការបង្កើតក្រសួងពតិមាន
- យោងលិខិតស្នើសុំបើកអាជីវកម្មរោងពុម្ព "ខែម ការ៉ូ" ចុះថ្ងៃទី ០៤ /៧/១៩៩៧ របស់លោក ខៀវ ថេន

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យលោក **ខៀវ ថេន** ស្ថិតនៅផ្ទះលេខ ១១A ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ "ខែមការ៉ូ" ដែលមាន ទីតាំងស្ថិតនៅអាស័យដ្ឋានខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវគោរពតាមកិច្ចសន្យាសមស្របតាមទំនៀមទំលាប់ សន្តិសុខសណ្តាប់ធ្នាប់សង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ២ សាមីខ្លួនត្រូវ ទទួលទោសតាមច្បាប់ជាធរមាន

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ-សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុក្រសួងពតិមាននិងប្រធានមន្ទីរពតិមានរាជធានីភ្នំពេញត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

៥- ទីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៣៣៩/សសរ កសក

ស្តីពី

ការប្រគល់ភារកិច្ចបន្ថែមបណ្តោះអាសន្នជូន ឯកឧត្តម

អនុរដ្ឋលេខាធិការ នាន់ សាផាន និង ឯកឧត្តម ឃុន សាវឿន

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលប្រកាស ឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១០៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ១៩៨៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញសេចក្តីសំរេចលេខ ២២៥ សសរ/កសក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- ដោយឯកឧត្តមអនុរដ្ឋលេខាធិការ ម៉ៅ សំអឿន អវត្តមានគ្មានពតិមាន
- បានឃើញការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : រាល់ការងាររបស់បណ្តាអង្គភាពដែល ឯកឧត្តម **ម៉ៅ សំអឿន** អនុរដ្ឋលេខាធិការទទួលបន្ទុក ត្រូវបានប្រគល់ជូនឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ទទួលបន្ទុកបន្ថែមបណ្តោះអាសន្នមានដូចខាងក្រោម :

- ឯកឧត្តម **នាន់ សាផាន** ទទួលបន្ទុកបន្ថែមការងារ :
- នាយកដ្ឋានជលផល
- គ្រឹះស្ថានសិក្សាកសិកម្ម

- ឯកឧត្តម **ឈុន សារ៉េត** ទទួលបន្ទុកបន្ថែមការងារ :
- នាយកដ្ឋានគ្រឿងយន្តកសិកម្ម

ប្រការ ២ : ឯកឧត្តម **ឆាន់ សាផាន** ឯកឧត្តម **ឈុន សារ៉េត** ឯកឧត្តមអគ្គនាយក និងឯកឧត្តម លោកប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទត្រូវអនុវត្ត សេចក្តីសំរេចនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ឈារ សុខ

* * *

៦- ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃ ទី ១៣ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៧៦ ប្រក/វវស.ប

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញសេចក្តីត្រូវការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងលោក **នី យ៉េង** ជាទីប្រឹក្សា ឯកឧត្តមរដ្ឋមន្ត្រី ទទួលបន្ទុកការងារសាកល វិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បន្ថែមលើភារកិច្ចបច្ចុប្បន្ន ។

ប្រការ ២ : ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ សាកលវិទ្យាល័យភូមិន្ទវិចិត្រ សិល្បៈ ព្រមទាំងលោក នី យ៉ាង មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

នុត ណារ៉ាំង

* * *

៧. និស្ដិការរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃ ទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៤០ បគ/ប្រក

ស្ដីពី

ការតែងតាំងបដិភ្នាក់ការៈមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្ដេច នរោត្តម សីហនុវរ្ម័ន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលលេខ ០៦ នស ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/២០ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ប្រកាសឱ្យប្រើដោយច្បាប់ ស្ដីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ និងប្រកាសឱ្យប្រើនៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញប្រកាសលេខ ០៨២ ប្រក/បទ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ រចនាសម្ព័ន្ធមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខ្សែរយៈបណ្ដោយគ្រប់ ខេត្ត-ក្រុង
- បានឃើញសារទូរលេខ លេខ ៣២៩/៩៧ ល.អខ ចុះថ្ងៃទី ០៦/៨/៩៧ របស់អភិបាល ខេត្តរតនគិរី

សំរេច

ប្រការ ១ : តែងតាំងលោក **វេជ ពិសិដ្ឋ** ជាបជិត្តាហាកៈរងប្រចាំប៉ុស្ដិ៍មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តរតនគិរី ។

ប្រការ ២ : បជិត្តាហាកៈមានភារកិច្ចរួមសហការ និង ទទួលខុសត្រូវលើការងារសេវាកម្ម អាជីវកម្ម ប្រៃសណីយ៍ និងទូរគមនាគមន៍ ទូទាំងខេត្ត-ស្រុក ជូនមុខឱ្យក្រសួង ។

ប្រការ ៣ : ខុទ្ទកាល័យអធិការដ្ឋាន នាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញកិច្ច មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តរតនគិរី និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្ត តាមខ្លឹមសារនៃប្រកាសនេះ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

៨. និស្ដីការក្រសួងធម្មការ និង សាសនា

សេចក្ដីសំរេច

រាជធានីភ្នំពេញ ថ្ងៃ ទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

សេចក្ដីសំរេចលេខ ១៨៧/៩៧ ក.ធ.ស

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខនស/រកម/១០៩៦..១៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលលេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងធម្មការ និងសាសនា

- បានឃើញពាក្យសុំបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ ក្រុមប្រឹក្សាសម្ព័ន្ធ គ្រិស្តបរិស័ទកម្ពុជា របស់លោក ស តា ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៧
- បានឃើញចំណារបញ្ជូន របស់ឯកឧត្តមអភិបាល ខេត្តបាត់ដំបង លេខ ៥៧៤ ខ.ប.ប ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ ក្រុមប្រឹក្សាសម្ព័ន្ធ គ្រិស្ត បរិស័ទកម្ពុជា ឈ្មោះ ហៅថា : "គ្រិស្តបរិស័ទដំណឹងល្អខេត្តបាត់ដំបង" មួយកន្លែង ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ ២៧៦ ក្រុមទី ២៦ ភូមិកំពង់ក្របី ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃព្រះវិហារឈ្មោះ " **គ្រិស្តបរិស័ទដំណឹងល្អ ខេត្តបាត់ដំបង** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិ សាសនាគ្រិស្តដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារ "គ្រិស្តបរិស័ទដំណឹងល្អខេត្តបាត់ដំបង" ត្រូវគោរពនិង អនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព នឹងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាត មិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា-មន្ទីរធម្មការ និងសាសនា ខេត្តបាត់ដំបង និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្ត សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ប្រការ ៦ : សេចក្តីសំរេចនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀន វណ្ណរ័ត្ន

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល